## គម្រោងគាំទ្រសេវាអប់រំកុមារនៅតំបន់ដាច់ស្រយាល

## (អេស្កាប់)

EQUIP1
Educational Quality Improvement Program
Classrooms • Schools • Communities

# ការធ្វើផែនការអភិវឌ្ឍន៍កម្រងសាលារៀន




### ការធ្វើផែនការកម្រងដើម្បីសំរេចឱ្យបាន
### នូវបរិស្ថានរៀនសូត្របែបសាលាកុមារមេត្រី

ឆ្នាំសិក្សា ២០០៥ ២០០៦

***សៀវភៅសំរាប់អ្នកសម្របសម្រួល***

# កម្មវិធីសិក្ខាសាលា

| ល.រ | ខ្លឹមសារមេរៀន | រយៈពេល |
|---|---|---|
| | **ថ្ងៃទី ១** | |
| **1** | ការចាប់ផ្តើមសិក្ខាសាលា | |
| 1.1 | ការណែនាំឱ្យស្គាល់គ្នា | ១០ នាទី |
| 1.2 | គោលបំណងសិក្ខាសាលា | ៥ នាទី |
| 1.3 | ការបង្ហាញពី គោលដៅ រចនាសម្ព័ន្ធ និងយុទ្ធវិធីប្រតិបត្តិការងាររបស់ អេស្កាប់ | ៣០ នាទី |
| **2** | **ការបង្ហាញពីគំនិត និងទស្សនៈនៃសាលាកុមារមេត្រី** | ៤៥ នាទី |
| **3** | **សមាសធាតុ និងលក្ខណៈនៃផែនការ** | ៣០ នាទី |
| **4.** | **ការកំណត់បញ្ហា** | |
| 4.1 | ការចាប់ផ្តើមធ្វើផែនការ ដោយផ្តោតទៅលើបញ្ហា | ១៥ នាទី |
| 4.2 | ដើមឈើបញ្ហា | ៦០ នាទី |
| 4.3 | ការវិភាគបញ្ហាចម្បង នៅក្នុងវិស័យអប់រំ | ៩០ នាទី |
| **5.** | **ការវិភាគគោលដៅ** | ៣០ នាទី |
| **6.** | **ការកំណត់កត្តាខាងក្រៅ** | ៣០ នាទី |
| | **ថ្ងៃទី ២** | |
| **7.** | **តារាងផែនការ** | ៣០ នាទី |
| **8.** | **ការសរសេរសកម្មភាព និងការប្រើបញ្ជីសេវាកម្ម** | |
| 8.1. | ការជ្រើសរើសសកម្មភាពដើម្បីសម្រេចគោលដៅ | ៦០ នាទី |
| 8.2 | ការសរសេរសកម្មភាពនៃផែនការ ដោយប្រើបញ្ជីសេវាកម្ម | ១២០ នាទី |
| **9.** | **ការសរសេរកត្តាចង្អុលបង្ហាញ** | ៩០ នាទី |
| | **ថ្ងៃទី ៣** | |
| **10.** | **ការកំណត់ធនធានសម្រាប់ធ្វើផែនការ** | ៣០ នាទី |
| **11.** | **អ្នកពាក់ព័ន្ធ ម្ចាស់កម្មសិទ្ធិ និងការចូលរួម** | |
| 11.1 | ទស្សនៈ និងគំនិតសំខាន់ៗ : អ្នកពាក់ព័ន្ធ ម្ចាស់កម្មសិទ្ធិ ការធ្វើផែនការដោយមានការចូលរួម | ១៥ នាទី |
| 11.2 | ទស្សនៈ និងគំនិតនៃអ្នកពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានសាលារៀន | ៤៥ នាទី |
| 11.3 | ចំណាប់អារម្មណ៍របស់ម្ចាស់កម្មសិទ្ធិ | ៣០ នាទី |
| 11.4 | របៀបនៃការគ្រប់គ្រងដោយមានការចូលរួម និងមិនមានការចូលរួម | ៤៥ នាទី |
| **12.** | **តារាងផែនការលំអិត** | ១៨០ នាទី |
| **13.** | **ជំហ៊ានបន្ទាប់** | ១៥ នាទី |

ពេលម៉ោងសម្រាប់សិក្ខាសាលាក្នុងថ្ងៃនីមួយៗ 7:30-11:00 3 ម៉ោងកន្លះ និង 1:30 – 4:30 3 ម៉ោង

សរុប **6 ម៉ោងកន្លះ (សំរាក 30 នាទី ) ក្នុងមួយថ្ងៃ**

# ថ្ងៃទី ១

| វគ្គទី ១: ការចាប់ផ្ដើមសិក្ខាសាលា | | |
|---|---|---|
| ខ្លឹមសារ និង សេចក្ដីសង្ខេប<br><br><br><br>រយៈពេល | ១.១. ការបង្ហាញរបស់អ្នកសម្របសម្រួល ចាប់ផ្ដើមសិក្ខាសាលា: ផ្នែកនេះអ្នកសម្របសម្រួលរៀបចំឱ្យ អ្នកចូលរួមធ្វើការណែនាំខ្លួន បង្ហាញគ្នាទៅវិញទៅមក ហើយ បង្ហាញពីខ្លឹមសារ កាលវិភាគ និងបង្កើតវិន័យសម្រាប់សិក្ខាសាលា ។<br><br><br>*១៥ នាទី* | |
| សម្ភារត្រូវការ | - ក្រដាសផ្ទាំងធំ<br>- ហ្វឺតក្ដារខៀន និងហ្វឺតក្រដាស | |
| គោលបំណង | សកម្មភាពអ្នកសម្របសម្រួល | សកម្មភាពអ្នកចូលរួម |
| -ធ្វើឱ្យសិក្ខាកាមបានស្គាល់ គ្នាទៅវិញទៅមក ។<br>- សិក្ខាកាមទាំងអស់បានចូលរួមពិភាក្សា ។<br>- សិក្ខាកាមទាំងអស់បានឯកភាពពីវិន័យ និងកម្មវិធីរបស់សិក្ខាសាលា ។ | <u>**ការណែនាំឱ្យស្គាល់គ្នា**</u><br>- អ្នកសម្របសម្រួលផ្ដើមស្វាគមន៏កក់ក្ដៅដល់ សិក្ខាកាមទាំងអស់ ហើយធ្វើការណែនាំខ្លួនម្ដងម្នាក់ៗ ធ្វើដូចនេះអ្នកសម្របសម្រួលងាយចាត់ចែងជាក្រុម ហើយធានាដល់ការចូលរួមពិភាក្សារបស់សិក្ខាកាម ទាំងអស់ដែរ ។<br><u>**ការរៀបចំចាត់ចែងក្រុម**</u><br>- បន្ទាប់ពីការណែនាំខ្លួនរួច អ្នកសម្របសម្រួលធ្វើការរៀបចំសិក្ខាកាមតាមក្រុមរបស់ពួកគេ ។ ឧទាហរណ៍-មុខតំណែងអាជ្ញាធរសមត្ថកិច្ចដាក់អង្គុយជាមួយគ្នាមួយក្រុម(ដូចជា: ប្រធានភូមិ នាយកសាលាជាដើម) គ្រូបង្រៀនមួយក្រុម តំណាងសហគមន៍ ក្រុមនិយាយ ភាសាជនជាតិមួយក្រុម ។ល ។<br><u>**វិន័យសម្រាប់សិក្ខាសាលា**</u><br>- អ្នកសម្របសម្រួលគប្បីសួរបញ្ជាក់បន្ថែម ពីវិន័យរបស់សិក្ខាសាលាដូចខាងក្រោម:<br>o ម៉ោងសិក្ខាសាលា<br>o ម៉ោងសម្រាក<br>o គម្រោងមេរៀន<br>o ការមានមតិមិនកាត់គ្នា<br>o ការមកដល់ និងការចាកចេញទៅវិញ<br>o ការលំអិតពីថវិកាឧបត្ថម្ភ<br>- បន្ទាប់ពីការពិភាក្សា សូមសរសេរលទ្ធផលលើក្រដាសផ្ទាំងធំ ហើយបិទបង្ហាញនៅលើជញ្ជាំងបន្ទប់ ។ | - សិក្ខាកាមម្នាក់ៗបង្ហាញខ្លួនដោយខ្លួនឯង<br>- សិក្ខាកាមស្វែងរកដៃគូ ដោយខ្លួនឯង<br><br>- ស្វែងរកការឯកភាព និងការកែប្រែវិន័យ |

| ខ្លឹមសារ និង សេចក្ដីសង្ខេប | **១.២. គោលបំណងសិក្ខាសាលា:** ផ្នែកនេះបង្ហាញអ្នកចូលរួមពីគោលបំណង គោលដៅ និងលទ្ធផលរំពឹងទុក របស់វគ្គសិក្ខាសាលា។ | |
|---|---|---|
| **រយៈពេល** | *៥ នាទី* | |
| **សម្ភារត្រូវការ** | - ផ្ទាំងក្រដាសៈ គោលបំណង គោលដៅ និងលទ្ធផលទទួលបានពីសិក្ខាសាលា | |
| **គោលបំណងៈ** | **សកម្មភាពអ្នកសម្របសម្រួល** | **សកម្មភាពអ្នកចូលរួម** |
| - សិក្ខាកាមអាចពន្យល់ពី គោលបំណង គោលដៅរបស់ សិក្ខាសាលា។<br>- សិក្ខាកាមអាចអធិប្បា យ ពីលទ្ធផលពេញចិត្ត ដែលទទួលបាន ពីវគ្គ សិក្ខាសាលា។ | - អ្នកសម្របសម្រួលបិទផ្ទាំងក្រដាស គោលបំណង គោលដៅ និងលទ្ធផលទទួលបានពីសិក្ខាសាលាលើក្ដារខៀន។<br>- រំឭកឯកសារមេរៀនជាមួយសិក្ខាកាម។<br>- សួរសំនួរដើម្បីវាស់វែងការយល់ដឹង។<br>ឧទាហរណ៍:<br>ក-តើអ្វីសំខាន់បំផុតដែលសិក្ខាសាលានេះនឹងទទួលបាន?<br>ខ- តើកំឡុងពេលប៉ុន្មានទើបកម្រងធ្វើបានផែនការ<br>គ- តើគប្បីបង្កើតផែនការដោយរបៀបណា (ឧ. តើយើងគួរបង្កើតផែនការដោយខ្លួនឯងឬទេ?) | - សិក្ខាកាមរំឭកឡើងវិញពីអត្ថន័យ លើ ផ្ទាំងក្រដាស ឬចូលរួមស្ដាប់ ការបញ្ជាក់ពី ខ្លឹមសារដោយអ្នក សម្របសម្រួល។<br>- ចូលរួមឆ្លើយនឹងសំណួររបស់ អ្នកសម្របសម្រួល។<br>- ពិភាក្សាចំលើយនានាដើម្បីយល់ កាន់តែច្បាស់។ |

**ផ្ទាំងក្រដាសៈ** គោលបំណង គោលដៅ និងលទ្ធផលទទួលបានពីសិក្ខាសាលា

**គោលបំណងៈ**

គោលបំណងរបស់សិក្ខាសាលានេះគឺដើម្បីផ្ដល់នូវវេទិការមួយដែលអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងកម្រងគោលដៅបានជួបគ្នា ហើយ រៀនអំពីកម្មវិធីអេស្កាប់ សាលាកុមារមេត្រី និងការធ្វើផែនការអភិវឌ្ឍសាលារៀន។

**គោលដៅៈ**

- សិក្ខាកាមអាចពន្យល់បានពីគោលដៅ និងលក្ខណៈសំខាន់ៗរបស់កម្មវិធីអេស្កាប់។
- សិក្ខាកាមអាចអធិប្បាយពន្យល់ពីគោលការណ៍សំខាន់ៗនៃសាលាកុមារមេត្រី។
- សិក្ខាកាមទទួលបាននូវជំនាញធ្វើផែនការសមហេតុសមផល ដោយផ្ដោតលើគោលដៅ។

**សមិទ្ធិផល (លទ្ធផលរំពឹងទុក)**

សិក្ខាសាលានេះនឹងឈានដល់ការបង្កើតបាននូវផែនការកែលំអកម្រងសាលារៀនប្រចាំឆ្នាំមួយ ដោយផ្អែកលើដំណើរការចូលរួម របស់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានដាក់បញ្ចូលផងដែរនូវការលើកឡើងពីបញ្ហាសំខាន់ៗ គោលដៅ សកម្មភាព ធនធាន និង កត្តាចង្អុលបង្ហាញ និងអ្នកទទួលខុសត្រូវ។

| | |
|---|---|
| **ខ្លឹមសារ និង សេចក្ដីសង្ខេប**<br><br><br><br><br><br><br>**រយៈពេល** | **១.៣. ការបង្ហាញពី កម្មវិធីអេស្កាប់ គោលដៅកម្មវិធី រចនាសម្ព័ន្ធ និង យុទ្ធវិធីធ្វើការងារ**<br>ផ្នែកនេះបង្ហាញឱ្យសិក្ខាកាមបានដឹងច្បាស់ពី គោលដៅ និងផ្នែកបច្ចេកទេសរបស់កម្មវិធី អេស្កាប់ (គឺ ផ្នែកបង្ក ភាព-ងាយស្រួលចូលសាលារៀន និងគុណភាពអប់រំ ផ្នែកបំប៉នគ្រូ និងផ្នែក ភាពជាដៃគូររវាងសាលារៀន និងសហគមន៍) និងវិធីសាស្ត្រសំខាន់ៗមួយចំនួនដែលកម្មវិធីនឹងធ្វើ។ នេះគឺ : ១-មធ្យោបាយអភិវឌ្ឍន៍ដោយ ផ្អែកលើសិទ្ធិរបស់កុមារ ២-អនុវត្តដំណោះស្រាយដោយប្រើរចនាសម្ព័ន្ធមួយ ធានាដល់ការឯកភាពនៃអ្នក ពាក់ព័ន្ធ ៣-ផ្តល់ថវិកាឱ្យដល់កម្រង និង ៤-ការអនុវត្តការងារដោយឆ្លងកាត់តាមអ្នកពាក់ព័ន្ធមូលដ្ឋាន។<br>*៣០ នាទី* |
| **សម្ភារត្រូវការ** | - ផ្ទាំងក្រដាសៈ គោលដៅ និងរចនាសម្ព័ន្ធនៃកម្មវិធី<br>- ផ្ទាំងក្រដាសៈ តារាងម៉ាទ្រិកយុទ្ធសាស្ត្រ (តារាង១សម្រាប់ក្រុមនីមួយៗ)<br>- ឯកសារចែក ១: គោលដៅ ផ្នែកបច្ចេកទេស និងអន្តរាគមន៍ជាក់ស្ដែងនៃកម្មវិធី<br>- រូបភាពអន្តរាគមន៍បានជ្រើសរើស<br>- ប័ណ្ណដែលអធិប្បាយពិស្តារ ពីទិដ្ឋភាពនៃការអនុវត្តកម្មវិធី |

| គោលដៅ: | សកម្មភាពអ្នកសម្របសម្រួល | សកម្មភាពអ្នកចូលរួម |
|---|---|---|
| -សិក្ខាកាមអាច ពន្យល់ពី គោលដៅ របស់អេស្កាប់។<br>- សិក្ខាកាមអាច អធិប្បាយពីរចនា សម្ព័ន្ធ របស់ អេស្កាប់ ។<br>- សិក្ខាកាមអាច រៀបរាប់ឈ្មោះ យុទ្ធវិធី ចម្បងៗ ទាំង៤ ដែលនឹងត្រូវប្រើដោយអេស្កាប់ ក្នុងការប្រតិបត្តិ ការងារ។ | <u>**គោលដៅកម្មវិធី :**</u><br>ការចាប់ផ្ដើមផ្នែកនេះដោយសួរសំណួរស្ទាបស្ទង់មួយចំនួនពី លក្ខណៈនៃការផ្តល់ការអប់រំនៅក្នុងកម្រងដូចខាងក្រោមៈ<br>• ភាគរយកុមារនៅក្នុងកម្រងមិនបានចូលរៀនមានប៉ុន្មាន?<br>• ភាគរយនៃអ្នកស្នាក់នៅក្នុងកម្រងជាជនជាតិភាគតិច មានប៉ុន្មាន?<br>• តើសាលាមានគ្រូជាជនជាតិដើមភាគតិចប៉ុន្មាននាក់?<br>• តើកម្រងមានសកម្មភាពបំនិនជីវិតអ្វីខ្លះដែលបានអប់រំ ទាក់ទងទៅនឹងសហគមន៍?<br>• តើកម្រងមានគ្រូបង្រៀនគ្រប់គ្រាន់ដែរឬទេ?បើទេ. តើវាមានប្រសិទ្ធិភាព និងគុណភាពឬទេ?<br>o បន្ទាប់មក បង្ហាញផ្ទាំងក្រដាសបកស្រាយពីគោលដៅកម្មវិធី លើក្ដារខៀន។<br>o ផ្ដល់ការពន្យល់ពីគោលដៅដែលទាក់ទងការពិភាក្សាបញ្ហាអប់រំ នៅក្នុងកម្រងដែលទើបបានជួបប្រទះ។<br>o ទុកឱកាសឱ្យសិក្ខាកាមសួរពីអ្វីដែលបានពន្យល់។<br><u>**រចនាសម្ព័ន្ធកម្មវិធី :**</u><br>o ផ្ដល់ឯកសារមេរៀនដែលបានអធិប្បាយពីផ្នែកទាំង៣ នៅក្នុងកម្មវិធី អេស្កាប់:<br>• ផ្ដល់ការបំប៉នគ្រូ<br>• បង្ករភាពងាយស្រួលចូលរៀន និងគុណភាពអប់រំ<br>• ភាពជាដៃគូររវាងសាលារៀន និងសហគមន៍<br>o ពន្យល់សង្ខេបពីសកម្មភាពដែលនឹងធ្វើនៅក្នុងផ្នែកទាំង៣ នេះ ដោយផ្ដល់ | o សិក្ខាកាមឆ្លើយ សំណួ-រដែលទាក់ទង ទៅនឹ-ងសេវាអប់រំ នៅក្នុងកម្រង។<br><br><br><br><br><br><br><br>o សិក្ខាកាមសួរសំណួរសំខាន់ៗ។<br>o សិក្ខាកាមរំឭកឯកសារមេរៀន ដែលបានចែកឱ្យ។<br>o សិក្ខាកាមចំនាត់ថ្នាក់ រូបភាព ដែលបាន ទទួលក្នុងក្រុមធំ ហើយផ្គុំផ្ទាបិទ លើក្ដា-រខៀន។ |

ឧទាហរណ៍បញ្ជាក់ច្បាស់ការអន្តរាគមន៍ដោយ ប្រើរូបភាពបានផ្តល់អោយ ។

- o ដើម្បីសម្របសម្រួលការពន្យល់ សូមចែករូបភាពហើយផ្តល់ជា ឧទាហរណ៍នូវអ្វីជាសកម្មភាពជាក់លាក់នៃការអន្តរាគមន៍ នីមួយៗ ។
- O (តាមគ្រប់វិធី) ព្រោះ ការត្រួតពិនិត្យការយល់ដឹងរបស់សិក្ខាកាមអំពី គោលដៅ ពីផ្នែកនីមួយៗ ដោយ សួរទៅសិក្ខាកាមដើម្បីបញ្ជាក់ពីរូបភាព ផ្នែក និង អន្តរាគមន៍ដែលគេយល់ ។

**<u>យុទ្ធវិធីប្រតិបត្តិការងារ:</u>**

- o អ្នកសម្របសម្រួលគប្បីពន្យល់ថាកម្មវិធី អេស្តាប់មានដំណោះស្រាយ ឬ យុទ្ធវិធី៤ ។ ក្រោយមកគប្បីផ្តល់ការពន្យល់មួយ ចំពោះយុទ្ធវិធីនីមួយៗ ដោយឱ្យអត្ថបទខ្លីៗពីចរិតលក្ខណៈនីមួយៗនៃយុទ្ធវិធីទាំង៤ ។
- o ប្រើអត្ថបទសង្ខេបមានកំណត់សម្គាល់ខាងក្រោមដើម្បីពន្យល់ រាល់លក្ខណៈរបស់យុទ្ធវិធីនីមួយៗនៃយុទ្ធវិធីទាំង៤ នៅក្នុងការបង្កើតកម្មវិធី ។

1. **<u>យុទ្ធវិធីបញ្ជាក់លើសិទ្ធកុមារ និងសិទ្ធមនុស្ស</u>**

- យល់ដឹងពីតម្រូវការរបស់កុមារ ។
- ពិគ្រោះយោបល់ជាមួយសិស្សដើម្បីយល់ដឹងពីគំនិតរបស់គេ ។
- ការស្តាប់មតិយោបល់របស់កុមារ អំពីបញ្ហាសាលារៀន ។
- ការស្តាប់មតិយោបល់របស់សមាជិកសហគមន៍ ។
- ការជួយដល់មាតាបិតាសិស្សឱ្យមានការយល់ដឹងកាន់តែប្រសើរឡើង ពីតម្រូវការរបស់កុមារ ។
- ដំណោះស្រាយការងារកម្មវិធីដោយបើកចំហ និងមិនរង់ចាំតែចាប់កំហុស គឺទទួលរាល់គំនិតស្ថាបនា ។

2. **<u>សេរីភាពនៅក្នុងរចនាសម្ព័ន្ធ (ជម្រើស)</u>**

- គ្មាននរណាម្នាក់ត្រូវបានបង្ខំឱ្យចូលរួមក្នុងកម្មវិធី
- គ្រូខ្លះអាចរីករាយចូលរួមក្នុងកម្មវិធី ក្នុងពេលដែលអ្នកផ្សេងទៀតមិនចង់ ។
- សាលានីមួយៗអាចធ្វើសកម្មភាពផ្សេងគ្នាដែលសមស្របទៅនឹងតម្រូវការរបស់គេ ។
- ការប្រើមីនុយសេវាកម្ម ។

3. **<u>ការប្រើអំណោយកម្រង</u>**

- កម្រងនីមួយៗនឹងទទួលថវិកាទៅតាមទំហំសកម្មភាព ដែលគេបាន ជ្រើសរើស ។
- កម្រងទទួលប្រាក់សុទ្ធតាមខែនីមួយៗពីកម្មវិធីដោយប្រើទម្រង់បទដ្ឋានកំណត់ឱ្យ ។
- កម្រងអាចទទួលថវិកាបានដោយបង្ហាញសំណើរដែលធ្វើឡើងជាមួយ

- o សិក្ខាកាមរំឭក យុទ្ធវិធីដោះ ស្រាយដែលអេស្តាប់បានប្រើ ។

គណៈកម្មការ គឺមិនមែនធ្វើឡើងតែម្នាក់ឬពីរនាក់នោះទេ។

4. **ការប្រតិបត្តិដោយឆ្លងតាមរយៈគណៈកម្មការមូលដ្ឋាន :**

- កម្រងប្រតិបត្តិសកម្មភាពនឹងត្រូវធ្វើដោយគណៈកម្មការមូលដ្ឋាន មានៈ គណៈកម្មការកម្រង គណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ និង គណៈកម្មការទ្រទ្រង់សាលារៀន។
- អ្នកពាក់ព័ន្ធនៅមូលដ្ឋានរៀបចំអនុវត្តសកម្មភាពដោយ ផ្ទាល់អាស្រ័យទៅលើតម្រូវការពិតរបស់គាត់។

o អ្នកសម្របសម្រួលសួរបន្ថែមដោយបញ្ចូលលំហាត់មួយដើម្បី បង្កើនការយល់ដឹងរបស់ពួកគេ ចំពោះធាតុផ្សេងៗគ្នា នៃប្រព័ន្ធការងាររបស់កម្មវិធី។

o បែងចែកតារាងប្រៀបធៀបកិច្ចការរបស់កម្មវិធីដូចបាន បង្ហាញខាងក្រោមនេះ

**តារាងប្រៀបធៀប**

| | |
|---|---|
| 1.យុទ្ធវិធីបញ្ជាក់លើសិទ្ធកុមារ និងសិទ្ធិមនុស្ស | 2. សេរីភាពនៅក្នុងរចនាសម្ព័ន្ធ (ជម្រើស) |
| 3. ការប្រើអំណោយកម្រង | 4.ការប្រតិបត្តិដោយឆ្លងតាមរយៈគណៈកម្មការមូលដ្ឋានៈ |

o ពន្យល់ប្រាប់ថាពួកគេនឹងទទួលកញ្ចប់ប័ណ្ណដែលមានពាក្យ និងឃ្លាបញ្ជាក់ពីលក្ខណៈនៃយុទ្ធវិធីទាំង៤។

o សំណូមពរអ្នកចូលរួមរៀប ហើយដាក់ប័ណ្ណនោះត្រូវតាមកន្លែងយុទ្ធវិធីនីមួយៗក្នុងតារាង ប្រមាណ ៣០នាទី ដោយបែងចែក-ជាក្រុមតូច។

o អ្នកសម្របសម្រួលដើរចល័តមើលនិងជួយដល់ក្រុមនីមួយៗ។

ចំណាំ : ការជួយនេះមិនមានន័យថាប្រាប់ចំលើយនោះទេ។

o ការបង្ហាញក្នុងក្រុមធំ។

o ការងារជាក្រុម: សិក្ខាកាម ប្រើប័ណ្ណដែលអ្នកសម្របសម្រួលចែកឱ្យ ហើយធ្វើចំណាត់ថ្នាក់ ទៅតាមយុទ្ធវិធីដែលបាន បង្ហាញ។

| វគ្គទី ២: ការបង្ហាញពីទស្សនៈនៃសាលាកុមារមេត្រី | | |
|---|---|---|
| **ខ្លឹមសារ និង សេចក្តីសង្ខេប**<br><br>**រយៈពេល** | ទស្សនៈនៃសាលាកុមារមេត្រី ផ្នែកនេះបង្ហាញឱ្យសិក្ខាកាមបានដឹងច្បាស់ពីផ្នែកទាំង៦ នៃសាលាកុមារមេត្រី ក្នុងនោះ: **១-កុមារទាំងអស់បានចូលរៀន ២-ការសិក្សាប្រកបដោយប្រសិទ្ធភាព ៣-សុខភាព សុវត្ថិភាព និងការការពារ ៤-ការឆ្លើយតបនឹងយេនឌ័រ ៥- ការចូលរួមរបស់កុមារ គ្រួសារ និងសហគមន៍ និង ៦- ការគាំទ្រកម្មវិធីពីប្រពន្ធ័អប់រំ** និងបានបញ្ជាក់ច្បាស់ពីអត្ថន័យនៃផ្នែកនីមួយៗ។<br>សិក្ខាកាមធ្វើលំហាត់ផ្គូរផ្គងដោយ ប្រៀបធៀបឃ្លាដែលបានអធិប្បាយអត្ថន័យរបស់ផ្នែកនីមួយៗ នៃសាលាកុមារមេត្រី។<br><br>*៤៥នាទី* | |
| **សម្ភារត្រូវការ** | o ផ្ទាំងក្រដាសៈ ផ្នែកនីមួយៗនៃសាលាកុមារមេត្រី (សូមអាននៅផ្នែកខាងក្រោម)<br>o ជម្រាកក្រដាសឃ្លាដែលអធិប្បាយបញ្ជាក់ពីផ្នែកនីមួយៗនៃសាលាកុមារមេត្រី | |
| **គោលដៅ:** | **សកម្មភាពអ្នកសម្របសម្រួល** | **សកម្មភាពសិក្ខាកាម** |
| o សិក្ខាកាមអាច កំណត់អត្ថន័យ នៃផ្នែកទាំង៦ និងអ-ិជាសាលាកុមារមេត្រី។<br>o សិក្ខាកាមអាចផ្តុំសេចក្តីដែលពណ៌នាពីផ្នែកនៃ សាលាកុមារមេត្រី។ | **<u>ការបង្ហាញពីផ្នែកទាំង៦នៃសាលាកុមារមេត្រីៈ</u>**<br>- អ្នកសម្របសម្រួលបង្ហាញពីភាពសមហេតុសមផលដើម្បីការអភិវឌ្ឍន៍សាលារៀនជាសាលាកុមារមេត្រីដោយរំឭកឡើងវិញពីបញ្ហាមួយចំនួនដែលធ្វើឱ្យសាលាមិនមែនជាសាលាកុមារមេត្រីពេលបច្ចុប្បន្នសម្រាប់ការសិក្សារបស់កុមារ។<br>- ដឹកនាំការពិភាក្សាដោយប្រើសំណួរ (និងចំលើយពេញចិត្ត) ដូចខាងក្រោមៈ<br>• **ផ្នែកទី១:**<br>មូលហេតុអ្វីដែលធ្វើឱ្យកុមារមានអារម្មណ៍រៀនដោយ ខ្លួនឯងនៅភូមិរបស់គេ បើទោះបីគ្មានគ្រូក៏ដោយ (ចំលើយៈ ការសិក្សាគឺជាការលេងសប្បាយ ការទទួលពតិមាន ហើយកុមាររៀននូវអ្វីដែលគេចាប់អារម្មណ៍ ។ល។)។<br>• **ផ្នែកទី២:**<br>តើកុមារមិនបានទៅសាលាដោយសារអ្វី? (ចំលើយៈ ដោយសារពួកគេក្រីក្រមិនអាចទិញសម្ភារៈជាតម្រូវការ កុមារមិនអាចស្តាប់និងនិយាយភាសាដែលកំពុងប្រើនៅក្នុងសាលា កុមារពិការដោយប្រការណាមួយ)។<br><br>• **ផ្នែកទី៣:**<br>តើសុខភាពនិងបរិស្ថានជាបញ្ហាដល់ការសិក្សាឬទេ? (ចំលើយៈ កុមារមានហូបគ្រប់គ្រាន់អាចទ្រាំរៀនមេរៀនរបស់គេបាន កុមាររំភើបរីករាយទៅសាលា ហើយមិនមានអារម្មណ៍ភ័យខ្លាចចំពោះមិត្តភ័ក្តិ។ល។<br><br>• **ផ្នែកទី៤:** | o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួល ហើយពិភាក្សា |

| | | |
|---|---|---|
| | តើសាលាអាចមានសមភាពយេនឌ័រយ៉ាងដូចម្តេច? (ចំលើយៈ គឺគ្រូៗមិនមានការប្រកាន់រើសអើងពីភេទ នៅពេលសួរសំណួរ មានតួនាទីបុរស ស្ត្រីជាគំរូនៅសាលា កុមារមិនបែងចែកពីលក្ខណៈភេទរបស់ពួកគេ ឧ. លទ្ធភាពប្រើប្រាស់បន្ទប់អនាម័យ ។ល។)<br>• **ផ្នែកទី៥ៈ**<br>តើសាលាទទួលបានផលប្រយោជន៍អ្វីខ្លះ បើសិនមានការចូលរួមពីមាតាបិតាសិស្ស? (ចំលើយៈការសិក្សាត្រូវបានជួយជំរុញនៅផ្ទះ ប្រសិនបើសាលារៀនបានផ្តល់នូវពតិមានទាក់ទងការអប់រំបានច្រើន មាតាបិតាសិស្សជួយជំរុញកូនទៅរៀនទៀងទាត់ ។ល។<br>o សង្ខេបការពិភាក្សាខាងលើដោយដាក់បង្ហាញផ្ទាំងក្រដាសផ្នែកទាំង៦នៃសាលាកុមារមេត្រី ។<br><u>**លំហាត់ផ្គូរផ្គងពាក្យ**</u><br>o ចែកជម្រៀកក្រដាសប្រយោគបង្ហាញក្នុងឯកសារមេរៀនទៅឱ្យសិក្ខាកាម ។ ធានាឱ្យមានជម្រៀកក្រដាសនេះគ្រប់សម្រាប់សិក្ខាកាមម្នាក់ៗទទួលបានមួយសន្លឹក ។ រំពឹងថាសិក្ខាកាមផ្គុំជម្រៀកក្រដាសបាន១០ប្រយោគ ដែលមានន័យគ្រប់គ្រាន់ (បើមានសិក្ខាកាម២០នាក់) ។ ករណីច្រើនជាង២០នាក់ អ្នកសម្របសម្រួលត្រូវបង្កើតឃ្លាបន្ថែម ឬបង្កើនទ្វេរឡើងឱ្យគ្រប់ចំនួនសិក្ខាកាម ។<br>o រាប់សិក្ខាកាមក្នុងក្រុមបើសេសគូរអ្នកសម្របសម្រួលអាចចូលរួមបង្គ្រប់ ។<br>o ច្របល់ជម្រៀកក្រដាសប្រយោគរួចបែងចែកឱ្យសិក្ខាកាមម្នាក់ៗមួយសន្លឹក ។<br>o សុំឱ្យសិក្ខាកាមដើររកបំណែកពាក់កណ្តាលទៀតដើម្បីផ្គុំគ្នា(បំណែកក្រដាសផ្គូរផ្គង)ពេលដែលបានធ្វើដូច្នេះហើយ ពួកគេគួរពិភាក្សាជាមួយដៃគូរ ថាតើប្រយោគនោះមានន័យយ៉ាងដូចម្តេច ហើយធ្វើឱ្យការសិក្សា បានប្រសើរឡើងយ៉ាងដូចម្តេច និងវាស្ថិតនៅក្នុងផ្នែក ទីប៉ុន្មាន?<br>o ពេលចប់សកម្មភាពនេះ សិក្ខាកាមបង្ហាញប្រយោគពេញលេញដល់ក្រុមធំ ហើយប្រាប់ថាវាស្ថិតនៅក្នុងផ្នែកណាមួយ ។ | o សិក្ខាកាមពិនិត្យមើលក្រដាស Posterជាមួយអ្នកសម្របសម្រួល<br>o <u>ការងារក្រុម</u>ៈ សិក្ខាកាមផ្គូរផ្គងល្បះដែលពួកគាត់ទទួលបាន ជាមួយល្បះរបស់ដៃគូ ។<br>o ពិភាក្សាអំពីអត្ថន័យនៃល្បះនីមួយ និងបែងចែកថ្នាក់តាមផ្នែកនីមួយៗ (Dimension)នៃផ្នែកទាំង៥ដែលបានពិភាក្សា ពី-ខាងដើម ។<br>o សិក្ខាកាមបង្ហាញល្បះដែលបានផ្គូរផ្គងដល់ក្រុម ហើយពន្យល់ ។ |





**ស្ថានភាពពេលបច្ចុប្បន្ន**




| វគ្គទី ៣: សមាសធាតុនិងលក្ខណៈនៃផែនការ | | |
|---|---|---|
| **ខ្លឹមសារ និង សេចក្តីសង្ខេប** | ១.៣. លក្ខខ័ណ្ឌទូទៅ: ផ្នែកនេះស្វែងរកឱ្យឃើញថា សិក្ខាកាមបានដឹងរួចទៅហើយអំពីការធ្វើ ផែនការនិងបង្កើតបាននិយមន័យទូទៅមួយចំនួនអំពីលក្ខខ័ណ្ឌធ្វើផែនការ ។ សិក្ខាកាមអាចដឹងរួចហើយច-ំពោះ លំដាប់នៃវិធីសាស្ត្រធ្វើផែនការ( ការធ្វើផែនការឃុំ/សង្កាត់ ។ល ។) ដែលក្នុងនោះ លក្ខខ័ណ្ឌត្រូវបានកំណត់ដោយប្លែកៗគ្នា ។ ផ្នែកនេះនឹងខិតខំបង្កើតមូលដ្ឋាន ទូទៅមួយចំនួនក្នុងការប្រើពាក្យដើម្បីធ្វើផែនការ ។ | |
| **រយៈពេល** | ៣០នាទី | |
| **សម្ភារត្រូវការ** | o ឯកសារចែកទី២: ការកំណត់ពាក្យទូទៅក្នុងការធ្វើផែនការ | |
| **គោលដៅ:** | **សកម្មភាពអ្នកសម្របសម្រួល** | **សកម្មភាពអ្នកចូលរួម** |
| o សិក្ខាកាមអាច ប្រើពាក្យក្នុងការធ្វើ ផែនការតាមវិធីមួយត្រឹមត្រូវ ។ | ការពិនិត្យមើលបទពិសោធការធ្វើផែនការមុនៗ<br>o ចាប់ផ្តើមមេរៀនដោយសួរសិក្ខាកាមថាតើ ពួកគាត់បានទទួលវគ្គបណ្តុះបណ្តាលអ្វីខ្លះកាលពីមុន ។ កំណត់ឱ្យបានច្បាស់ថាតើសិក្ខាកាម បង្ហាញខ្លឹមសារត្រឹមត្រូវស្តីអំពីវគ្គប៉ុន្មានដែល អាចជួយគាត់កំណត់បានអំពីវិធីធ្វើផែនការដែលអាចប្រើប្រាស់បាន ។<br><u>ចំលើយមាន</u><br>គ្រូបង្រៀនថ្នាក់គួបផ្អែកលើព័ត៌មាន<br>ផែនការសមហេតុផល | o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួល ។ |

| | | |
|---|---|---|
| | ការធ្វើផែនការឃុំ/សង្កាត់<br>ផ្សេងៗ<br>o ព័ត៌មាននេះជួយឱ្យអ្នកសម្របសម្រួលបែងចែកកំរិតបទពិសោធនៃការធ្វើផែនការរបស់គាត់ ។ ឧទាហរណ៍ ប្រសិនបើមាននាយកសាលា ទទួលបន្ទុកផ្នែក CEFAC ពួកគាត់ប្រហែលជាបានទទួលវគ្គតម្រង់ទិសអំពីការកសាងផែនការ LFA ក្នុងរយៈពេលធ្វើការងាររបស់គាត់ ។ សមាជិកក្រុមប្រឹក្សាឃុំប្រហែលជាមានវិធីធ្វើផែនការ សាមញ្ញជាងនេះ ។<br>ការស្រង់ពាក្យបច្ចេកទេស<br>o **ចែកឯកសារទី ៧** ហើយឱ្យសិក្ខាកាមមើលបញ្ជីពាក្យបច្ចេកទេសនៃផែនការដែលបានបង្ហាញ នៅខាងលើនៃទំព័រ ហើយបែងចែកពាក្យ ដែលអាចទទួលយកបាននៅក្នុង Matrix នៅ ក្រោមបញ្ជី ។ ពិនិត្យឧទាហរណ៍ដែលផ្តល់ ឱ្យ ជាក្រុមធំ ។<br>o ពិនិត្យមើលការឡើងបង្ហាញរបស់ក្រុម ហើយសម្របសម្រួលចំលើយ ។<br>o ក្នុងការឡើងបង្ហាញរបស់ក្រុម អ្នកសម្រប សម្រួលមានតួនាទីសម្របសម្រួលអត្ថន័យនៃពាក្យបច្ចេក-ទេស និងបង្កើតក្រុមពាក្យសាមញ្ញនៃការធ្វើផែនការ ។ ខាងក្រោមនេះគឺជាការណែនាំអំពីអត្ថន័យ និងពាក្យដែលបានសម្របសម្រួលជាលើកចុងក្រោយសម្រាប់ប្រើនៅក្នុងវគ្គកសាងផែនការនេះ ។<br>**ចំលើយ** — **ពាក្យចុងក្រោយ**<br>១.បញ្ហា, តម្រូវការ — **បញ្ហា**<br>២.គោលបំណង, គោលដៅ — **គោលដៅ**<br>៣. ផល, លទ្ធផល, ដំណោះស្រាយ — **ដំណោះស្រាយ**<br>៤.ធនធាន, ទិន្នផល — **ធនធាន**<br>៥.ការសន្និដ្ឋាន, កត្តាកំណត់ខាងក្នុង — **គ្មាន**<br>៦.សកម្មភាព, ដំណោះស្រាយ — **សកម្មភាព**<br>៧.កត្តាចង្អុលបង្ហាញ, អាំងឌីកាទ័រ — **កត្តាចង្អុលបង្ហាញ** | o លំហាត់ក្រុមតូចៈ ដោយប្រើឯកសារទី ៧ សិក្ខាកាមត្រូវបែងចែកពាក្យបច្ចេកទេសនៃការធ្វើផែនការដែលមានលក្ខណៈស្រដៀងគ្នានៅក្នុង Matrix ។ ក្រុមទាំងអស់អាចបង្កើតបញ្ជីផ្សេងៗគ្នានៃពាក្យបច្ចេកទេសដែលបានផ្ទៀងផ្ទាត់រួច ។ ចំលើយ របស់ក្រុមនីមួយៗត្រូវដាក់បញ្ចូល គ្នាតាមអត្ថន័យដែលបានបកស្រាយនៅក្នុងអត្ថបទមុនៗ ។ ចំពោះចំណុចនេះ នៅក្នុងការពិភាក្សាពុំមានចំលើយត្រូវ ឬខុសទេ ។ នៅពេលពិភាក្សារួច ក្រុមនីមួយៗត្រូវបង្ហាញចំលើយ ។<br><br>o លំហាត់ពិភាក្សាក្រុមធំៈ សូមផ្ទៀងផ្ទាត់ពាក្យដែលបានសម្រួលលើកចុងក្រោយជាមួយនឹងនិយមន័យដែលបានផ្តល់នៅក្នុងតារាងទី២នៅក្នុងឯកសារទី ៧ ។ |

| | | |
|---|---|---|
| | នៅពេលការសម្របសម្រួលពាក្យបានចប់ អ្នកសម្របសម្រួលត្រូវសង្កត់ធ្ងន់លើការរៀននេះ ដោយឱ្យសិក្ខាកាមបំពេញលំហាត់នៅក្នុង តារាងទី២នៅក្នុងឯកសារទី ៧ ។ សូមអាន និយមន័យដែលបានផ្តល់ឱ្យ ហើយជ្រើសរើស ពាក្យចេញពីតារាងពាក្យដែលបានសម្របសម្រួល លើកចុងក្រោយដែល មានន័យសមបំផុតនឹង និយមន័យ ។ ធ្វើលំហាត់នេះជាក្រុមធំ ។ | |

| **វគ្គទី ៤: ការកំណត់បញ្ហា** | | |
|---|---|---|
| ប្រធានបទ<br>និង ការសង្ខេប<br><br>ពេលវេលា | **៤.១. ការចាប់ផ្តើមធ្វើផែនការ** – ការចាប់ផ្តើមជាមួយបញ្ហាៈ នេះគឺជាវគ្គពិភាក្សាខ្លីមួយ ។ អ្នកសម្របសម្រួលពន្យល់ថា គោលដៅមានសារៈសំខាន់ណាស់សម្រាប់កសាងផែនការ ហើយវានឹងនាំឱ្យយើងចេញផុតអំពីបញ្ហា។ តាមពិត មានគោលដៅមួយផ្ទុយពីបញ្ហា ។ អ្នកសម្រសម្រួល ព្យាយាមផ្តល់ឧទាហរណ៍ខ្លះដែលទាក់ទងនឹងបញ្ហា និងគោលដៅ ហើយជួយឱ្យសិក្ខាកាមរកឱ្យឃើញថា តើបញ្ហាមួយៗវាខុសគ្នាយ៉ាងដូចម្តេច ។ ការពិភាក្សានេះមានប្រយោជន៍សម្រាប់មេរៀនក្រោយ — **ដើមឈើបញ្ហា** ។<br><br>*១៥នាទី* | |
| សម្ភារត្រូវការ | o គ្មាន | |
| គោលដៅ | ការបង្ហាញ | សកម្មភាពរបស់សិក្ខាកាម |
| o សិក្ខាកាមអាច ពន្យល់ពី មូលហេតុ ថាតើហេតុអ្វី បានជាវាន័យគ្រប់គ្រាន់ សម្រាប់ចាប់ផ្តើមធ្វើ ផែន-ការដោយមើលទៅ បញ្ហា ។ | **<u>ការបង្កើតជាបណ្តុំ</u>** ការកំណត់ធាតុសំខាន់នៅក្នុងផែនការមួយ<br>o ប្រាប់សិក្ខាកាមថា វគ្គក្រោយនេះពន្យល់អំពីវិធីធ្វើផែនការអភិវឌ្ឍសាលាដែលប្រើការវិភាគ។ ជំហ៊ានទាំងអស់ដែលបានពិភាក្សាខាងក្រោមគេហៅថា LFA ចាប់ផ្តើមពិភាក្សាដោយឱ្យសិក្ខាកាមរកធាតុសំខាន់ៗនៃការធ្វើផែនការ ។ បង្កើតតារាងចំលើយដាក់នៅលើក្តារខៀន ។ នៅពេលសិក្ខាកាមរៀបរាប់ពីពាក្យ **គោលបំណង** ឬ **គោលដៅ** សុំឈប់ ហើយនិយាយពីអ្វីដែលបង្ហាញថា ការបង្កើតគោលដៅល្អគឺជាគន្លឹះនៃ ការបង្កើតផែនការល្អមួយ ។<br>**<u>ទំនាក់ទំនងរវាងបញ្ហា និងគោលដៅ</u>**<br>o សួរសិក្ខាកាមនូវសំណួរៈ **តើយើងអាចបង្កើត គោ-លដៅនៅក្នុងសាលារៀនរឺទេ ប្រសិនបើពុំមានបញ្ហា?** នៅក្នុងការពិភាក្សា អ្នកសម្របសម្រួល ត្រូវព្យាយាមសង្កត់ធ្ងន់ថា ប្រសិនបើសាលានោះមាន | o សិក្ខាកាមស្តាប់ការបកស្រាយរបស់អ្នកសម្របសម្រួល និងឆ្លើយនឹងសំណួរ ។<br><br>o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួល ហើយពិភាក្សាអំពីទំនាក់ទំនងរវាងបញ្ហា និង |

| | | |
|---|---|---|
| | បញ្ហាមែន វាប្រាកដជាលំបាកក្នុងការបង្កើតគោលដៅ ព្រោះគោលដៅតែងដឹកនាំដល់ការដោះស្រាយបញ្ហា។ តាមពិត **គោល** គឺជាពាក្យផ្ទុយនឹងពាក្យ **បញ្ហា** — *វាគឺពាក្យបញ្ហាសពីបដិសេធទៅជាស្រប ។*<br><br>ឧទាហរណ៍:<br><br>*បញ្ហា* → *<u>គោលដៅ</u>*<br>សិស្សគ្មានសៀវភៅសិក្សាគោល → សិស្សមានសៀវភៅសិក្សាគោល<br><br>o ការពិភាក្សានេះគួរតែធ្វើឱ្យសិក្ខាកាមយល់បាន ថា-ការសរសេរគោលដៅនៅក្នុងផែនការប្រចាំឆ្នាំមួយត្រូវពឹងផ្អែកលើការយល់ដឹងក្បោះក្បាយអំពីបញ្ហា ។<br>o បន្ទាប់មកអ្នកសម្របសម្រួលត្រូវសួរសិក្ខាកាមនូវសំណួរមួយទៀត: **តើបញ្ហាតែងតែដូចគ្នារឺ?** សូមដឹកនាំការពិភាក្សានេះ ហើយជួយឱ្យសិក្ខាកាមយល់ថា បញ្ហាមួយចំនួនអាចមានសារៈសំខាន់ជាងបញ្ហាដទៃ បញ្ហាមួយចំនួនអាចមិនសំខាន់ បញ្ហាមួយចំនួនអាចជាលទ្ធផល បញ្ហាមួយចំនួនអាចជា **មូលហេតុ** ផង និងលទ្ធផលផងក្នុងពេលតែមួយ ។ | គោលដៅ ។<br><br>o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួល ហើយពិភាក្សាពីលក្ខណៈខុសៗគ្នាពីបញ្ហាមួយទៅបញ្ហាមួយទៀត ។ |

| | | |
|---|---|---|
| **ប្រធានបទ និង ការសង្ខេប**<br><br>**ពេលវេលា** | **៤.២. ដើមឈើបញ្ហា:** អ្នកសម្របសម្រួលចាប់ផ្ដើមដោយសុំយោបល់ពីសិក្ខាកាមអំពីបញ្ហា សាមញ្ញនៅក្នុងសាលារៀន ហើយចងក្រងជាបញ្ជីទូទៅមួយ ។ អ្នកសម្របសម្រួលនិយាយថា គាត់នឹងបកស្រាយបង្ហាញអំពីវិធីមើលបញ្ហាឱ្យបានជ្រៅជ្រះ ពោលគឺការវិភាគបញ្ហា ។<br>អ្នកសម្របសម្រួលពណ៌នាអំពីបច្ចេកទេសនៃ **ដើមឈើបញ្ហា** ហើយបកស្រាយអំពីវិធីអនុវត្តតាមរយៈឧទាហរណ៍ដែលមិនទាក់ទងនឹងការអប់រំ ។<br><br>*៣០នាទី* | |
| **សម្ភារត្រូវការ** | o **ឯកសារចែកទី ៣: ការវិភាគដើមឈើបញ្ហា**<br>o ប័ណ្ណបញ្ហាដែលមានអក្សរ (ដកស្រង់ពីឧទាហរណ៍ដែលមិនទាក់ទងនឹងការអប់រំ) | |
| **គោលដៅ** | **ការបង្ហាញ** | **សកម្មភាពរបស់សិក្ខាកាម** |
| o សិក្ខាកាមអាចវិភាគដើមឈើបញ្ហា ដោយប្រើវិធីនៃដើមឈើបញ្ហា ។ | **<u>សមាសធាតុនៃដើមឈើបញ្ហា</u>**<br>o អ្នកសម្របសម្រួលនិយាយថាវគ្គនេះគឺស្ដីអំពីការកំណត់ និងការវិភាគបញ្ហា ។ | o សិក្ខាកាមស្ដាប់កាលបង្ហាញរបស់អ្នកសម្របសម្រួល |

| | | |
|---|---|---|
| o សិក្ខាកាមអាចកំណត់ធាតុសំខាន់ ខ្លះៗនៃដើមឈើបញ្ហា ដូចជាបញ្ហាចម្បង បញ្ហាបន្ទាប់បន្សំ និងបញ្ហាដែលបង្ហាញពីលទ្ធផល ។ | o ដើម្បីដោះស្រាយបញ្ហា យើងត្រូវការយល់ពីការកំណត់ និងការវិភាគនេះឱ្យបានច្បាស់លាស់ ។ យើងអាចដោះស្រាយបានដោយការអនុវត្តធ្វើការវិភាគលើបញ្ហា ។<br>o អ្នកសម្របសម្រួលពន្យល់ថាល្បិចដែលល្អសម្រាប់វិភាគបញ្ហា និងជួយសរសេរគោលដៅ គឺ **ដើមឈើបញ្ហា**។ ដោយប្រើគំនិតនៃតួដើមឈើ (តួបញ្ហា) និងឫសច្រើន (មូលហេតុ) និង មែក/សាខា (លទ្ធផល) ជួយយើងឱ្យចេះវិភាគបញ្ហា (ឧ. កសិករក្រីក្រ) ។<br>**ដើមឈើបញ្ហា:** ឧទាហរណ៍<br>o អ្នកសម្របសម្រួលជ្រើសរើសតួបញ្ហាខុសគ្នា មួយ(មិនមែនស្តីអំពីបញ្ហាអប់រំ) និងវិភាគដើមឈើបញ្ហា នៃបញ្ហានោះ ដោយជជែកគ្នាអំពីអ្វី ដែលគាត់កំពុងធ្វើ ។ អ្នកសម្របសម្របប្រើសំណួរដើម្បី ឱ្យសិក្ខាកាមចូលរួមក្នុងការកំណត់មូលហេតុ និង លទ្ធផល ។ **ចែកឯកសារទី ២: ការវិភាគបញ្ហា** ដើម្បីសម្របសម្រួលដល់ការពន្យល់ ។<br>o អ្នកសម្របសម្រួលនិយាយដោយសាមញ្ញ ដើម្បីជួយឱ្យសិក្ខាកាមដែលពុំសូវយល់ ។ ចំពោះមូលហេតុ ត្រូវនិយាយថា "**កសិករក្រីក្រ ព្រោះ ...**" " ហើយចំពោះលទ្ធផល ត្រូវនិយាយថា ដោយសារកសិករក្រីក្រ ពេលនោះ..." ជំរើស: អ្នកសម្របសម្រួលអាច បកស្រាយ-ការអភិវឌ្ឍដើមឈើបញ្ហាដោយការសំដែង តួ-ជាអ្នកស្រុកភូមិពិភាក្សាពីបញ្ហានៅក្នុងស្រុក ។ បន្ទាប់ពីការពិភាក្សាខ្លី ពួកគេដាក់"**ផលស្រូវមានកម្រិតទាប**។" ជាបញ្ហាចម្បង ហើយធ្វើបន្ត ។ | ហើយឱ្យទាហរណ៍នៃបញ្ហាដែលប្រឈមមុខនៅក្នុងសាលារៀន ។<br><br>o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួលអំពីមូលហេតុ និងលទ្ធផលនៃបញ្ហាចម្បងនៃ "កសិករក្រីក្រ" ។ |

| | |
|---|---|
| **ប្រធានបទ និង ការសង្ខេប** | ៤.៣. **ការវិភាគបញ្ហាចម្បងនៅក្នុងការអប់រំ:** អ្នកសម្របសម្រួលសុំឱ្យសិក្ខាកាមកំណត់ថា តើអ្វីជាបញ្ហាដែលសំខាន់ជាងគេបំផុតនៅក្នុងកម្រងតាមការគិតរៀងៗខ្លួន ។ អ្នកសម្របសម្រួលព្យាយាមដឹកនាំការពិភាក្សាដែលជួយឱ្យក្រុមចេះកំណត់ថាតើបញ្ហាណា ដែលជាបញ្ហាសំខាន់ជាងគេបំផុត ។ ការពិភាក្សានេះត្រូវផ្តោតលើ **សិស្ស** ដែលនេះជាមូលហេតុនៃការដែលយើងមានសាលារៀន ។ ក្នុងចំណុចនេះ អ្នកសម្របសម្រួលត្រូវជួយក្រុមឱ្យមានការព្រមព្រៀងគ្នាស្តីអំពីបញ្ហាចម្បង បន្ទាប់មក ក្រុមត្រូវវិភាគបញ្ហា ដោយប្រើល្បិចដែលបានរៀបរាប់កាលពីខាងដើម ។ សកម្មភាពនេះនាំឱ្យមានការអភិវឌ្ឍនៃដើមឈើបញ្ហានៅក្នុងកម្រង ។ |
| ពេលវេលា | *90 នាទី* |

| សម្ភារត្រូវការ | o ប័ណ្ណ<br>o ហ្វឺត ស្កុត ក្រដាសផ្ទាំង<br>o ដីសពណ៌ | |
|---|---|---|
| **គោលដៅ** | **ការបង្ហាញ** | **សកម្មភាពរបស់សិក្ខាកាម** |
| o សិក្ខាកាមអាចកំណត់បញ្ហាចម្បងនៅក្នុងកម្រងបាន ។<br>o សិក្ខាកាមអាចវិភាគបញ្ហានៅក្នុងកម្រងដោយប្រើវិធីធ្វើដើម-ឈើបញ្ហា ។ | <u>ការកំណត់បញ្ហាចម្បងនៅក្នុងកម្រង</u><br>o អ្នកសម្របសម្រួលចែកប័ណ្ណ និងហ្វឺតឱ្យ សិក្ខាកាម ហើយឱ្យពួកគាត់សរសេរបញ្ហាមួយ ដែលពួកគេគិតថាជាបញ្ហាសំខាន់ជាងគេនៅក្នុងកម្រង។ ត្រូវកំណត់ថាពួកគេសរសេរចំលើយជាអក្សរធំដើម្បីឱ្យគ្រប់គ្នាអាចមើលឃើញ ច្បាស់។<br>o ពីរបីនាទីបន្ទាប់មក ប្រមូលប័ណ្ណ និងបិតដាក់នៅលើក្តារខៀន។ ដាក់ប័ណ្ណដែលប្រហាក់ប្រហែលគ្នាជាមួយគ្នាដើម្បីបង្រួមបញ្ហា ។<br>o ឱ្យសិក្ខាកាមពិចារណាព្រួញនៃបញ្ហាដែលបានកំណត់ ហើយព្យាយាមដឹកនាំការពិភាក្សាដែល ជួយឱ្យគ្រប់គ្នាព្រមព្រៀងលើបញ្ហាមួយ ដែលជា បញ្ហាចម្បង។ សកម្មភាពនេះ ត្រូវធ្វើ ដោយមាន ការព្រមព្រៀង។ តាមការសង្ឃឹមទុក សិក្ខាកាមនឹងជួបប្រទះបញ្ហាដែលទាក់ទងនឹងសុខមាលភាពរបស់សិស្ស ដូចជា **"សិស្សមិនចង់រៀន" "សិស្សនៅក្រៅសាលា"** ។ល។<br>**<u>វិភាគបញ្ហាសម្រាប់កម្រង</u>**<br>o បន្ទាប់ពីកំណត់បញ្ហាចម្បងរួច អ្នកសម្របសម្រួលត្រូវដាក់ប័ណ្ណបញ្ហាដែលបានជ្រើសរើស នៅចំកណ្តាលក្រដាសធំ ។ បន្ទាប់មកចាប់ផ្តើមកំណត់ថាតើបញ្ហាផ្សេងទៀតណាខ្លះជាមូលហេតុ និងបញ្ហាណាខ្លះជាលទ្ធផល ។ ចូរបន្ថែមបញ្ហា**ផ្សេងៗដែល** | o សិក្ខាកាមសរសេរនូវបញ្ហាដែល ពួកគាត់គិតថាជាបញ្ហាសំខាន់ ជាងគេនៅក្នុងកម្រងដាក់លើប័ណ្ណ ។<br>o សិក្ខាកាមពិភាក្សាពី បញ្ហាចម្បងដែលគាត់គិតថាជាបញ្ហាចម្បងក្នុងចំណោមបញ្ហាទាំងអស់ដែលបានចុះក្នុបញ្ជី ។ ក្រុមមានការព្រមព្រៀងគ្នាតាមរយៈការសម្រេចចិត្ត ។<br>o សិក្ខាកាមវិភាគបញ្ហាដោយប្រើវិធីដើមឈើបញ្ហាតាមស្ថានភាពនៃកម្រងរបស់ពួកគាត់ ។ |
| | សិក្ខាកាមបានគិត។ សុំភ្ជាប់បញ្ហាជាមួយនឹងដីសពណ៌។ សកម្មភាពនេះនឹងធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងងាយស្រួលនៅក្នុងដ្យាក្រាម ដោយលុបគំនូស-ដីសចាស់ចោល ។<br>- ត្រួតពិនិត្យ និងជួយសិក្ខាកាមក្នុងកិច្ចការនេះ ហើយត្រូវសួរឱ្យច្បាស់ថាតើការផ្លាស់ប្តូរបញ្ហា វាត្រឹមត្រូវឬទេ ។ | |

| វគ្គទី ៥: ការវិភាគគោលដៅ | |
|---|---|
| ប្រធានបទ និង | **ការសរសេរគោលដៅដើម្បីផ្លូវផ្តងជាមួយបញ្ហា:** នេះជាវគ្គមួយដែលសិក្ខាកាមនឹងរៀនអំពីវិធីផ្លាស់ប្តូរបញ្ហាទៅជាគោលដៅ ពីលក្ខណៈបដិសេធទៅជាលក្ខណៈស្រប ។ អ្នកសម្របសម្រួល ណែនាំវគ្គ និងបកស្រាយបង្ហាញពីការផ្លាស់ប្តូរបញ្ហាឱ្យទៅជាគោលដៅដោយប្រើតារាងដែលបានរៀបចំរួច។ បន្ទាប់មកសិក្ខាកាមផ្លាស់ប្តូរទាំងនោះនៅក្នុងដើមឈើបញ្ហាឱ្យទៅជាគោលដៅ ។ |
| ការសង្ខេប | |
| ពេលវេលា: | *45 នាទី* |
| សម្ភារត្រូវការ | o **ឯកសារចែកទី ៤: ការវិភាគគោលដៅ**<br>o ប័ណ្ណ<br>o ហ្វឺត ក្រដាសផ្ទាំងធំ ស្កុត |

| គោលដៅ | ការបង្ហាញ | សកម្មភាពរបស់សិក្ខាកាម |
|---|---|---|
| o សិក្ខាកាមអាចប្តូរបញ្ហាឱ្យទៅជាគោលដៅដែលអាចប្រើប្រាស់បាននៅក្នុងផែនការរបស់គាត់ ។<br>o សិក្ខាកាមអាចកំណត់គោលដៅដែលអាចធ្វើបាននិងមិនអាចធ្វើបាន ។<br>o សិក្ខាកាមអាចកំណត់បានថាគោលដៅណាមានរយៈពេលវែង និងមួយណា រយៈពេលខ្លី ។ | <u>ការប្តូរបញ្ហាទៅជាគោលដៅ: ឧទាហរណ៍</u><br>o អ្នកសម្របសម្រួលបកស្រាយពីវិធីការ វិភាគដើមឈើបញ្ហា លើកមុន (**កសិករក្រីក្រ**) អាចត្រូវ បានផ្លាស់ប្តូរទៅជាគោលដៅដោយប្តូរបញ្ហាទាំងនោះពី បដិសេធទៅជាស្រប។ អ្នកសម្របសម្រួលបកស្រាយ ដោយផ្លាស់ប្តូរបញ្ហាមួយចំនួនទៅជាគោលដៅដោយជជែកគ្នាដើម្បីជួយឱ្យសិក្ខាកាមបានយល់កាន់តែច្បាស់ ។<br>o <u>**ចែកឯកសារ: ការវិភាគគោលដៅ**</u> និងឱ្យសិក្ខាកាមធ្វើលំហាត់ប្តូរបញ្ហាទៅជាគោលដៅដោយបំពេញកិច្ចការដែលបានចាប់ផ្តើមនៅខាងដើម ។<br>o ពិនិត្យចំលើយរួមគ្នា<br>o មើលគោលដៅ ស្រង់ចេញពីដើមឈើគោលដៅ។<br><u>ការវិភាគគោលដៅសម្រាប់កម្រុង</u><br>o អ្នកសម្របសម្រួលឱ្យសិក្ខាកាមជ្រើសរើសបញ្ហានៅក្នុងដើមឈើបញ្ហា ហើយប្តូរវាឱ្យទៅជាគោលដៅត្រូវកំណត់ឱ្យ បានច្បាស់ថាគោលដៅទាំងអស់មិនត្រូវ **ចាប់ផ្តើមដោយ កិរិយាស័ព្ទ** ។ សិក្ខាកាមត្រូវសរសេរគោលដៅផ្ទាល់ខ្លួន នៅលើប័ណ្ណពណ៌ ហើយបិតលើប័ណ្ណបញ្ហា ។ សកម្មភាព នេះនឹងបង្កើតដើ-មឈើ គោលដៅសម្រាប់កម្រុង ។<br>o ពិនិត្យ និងជួយប្រសិនចាំបាច់<br><u>ការពិនិត្យដើមឈើគោលដៅ</u> | o សិក្ខាកាមយល់ស្របតាមការពន្យល់របស់អ្នកសម្របសម្រួល ។<br>o សិក្ខាកាមបំពេញ លំហាត់ដែលមាននៅក្នុងឯកសារចែក ។<br>o សិក្ខាកាមប្តូរបញ្ហានៅក្នុងដើមឈើបញ្ហាទៅជាគោលដៅ ហើយបិតពីលើបញ្ហា ។ បែបនេះបង្កើតជាដើមឈើគោលដៅសម្រាប់កម្រុង ។<br>o សិក្ខាកាមអានដើមឈើ បញ្ហាទាំងអស់ជាមួយអ្នកសម្រប-សម្រួល ។ |

| | | |
|---|---|---|
| | o ពិនិត្យដើមឈើគោលដៅជាមួយសិក្ខាកាម។ អានដើមឈើបញ្ហា *ពីក្រោមឡើងលើ* ដើម្បីកំណត់ឱ្យច្បាស់ថា គោលដៅ មានលក្ខណៈត្រឹមត្រូវ ។ ពោលគឺ ដំបូងយើងត្រូវធ្វើឱ្យបានសម្រេចគោលដៅនៅខាងក្រោមដើម្បីសម្រេច ឱ្យបានគោលដៅនៅខាងលើ ។ ពិនិត្យមើលការសរសេរគោលដៅ ដើម្បីឱ្យគោលដៅទាំងនោះស្របនឹងសភាពជាក់ស្តែង (ឧ. គ្មានសិស្សបោះបង់ ជំនួសឱ្យសិស្សបោះបង់ថយចុះ) ។ លើសពីនេះ ត្រូវពន្យល់អំពីឋានានុក្រមនៃគោលដៅដែលបានបង្ហាញនៅក្នុងដ្យាក្រាម រួមមាន **គោលដៅរយៈពេលវែង គោលដៅរយៈពេលខ្លី** និង **លទ្ធផល** ។ សម្គាល់ថា ធម្មតាយើងដាក់គោលដៅនៅជួរទីមួយនៅក្រោម **គោលដៅរយៈពេលខ្លី** ជាលទ្ធផលសម្រាប់ហេតុផល ២។ ទីមួយ គោលដៅទាំងអស់នៅខាងក្រោម ត្រូវបានដាក់បញ្ចូលរួចហើយនៅក្រោម គោលដៅនីមួយៗក្នុងជួរទីមួយ។ ទីពីរ សកម្មភាពនេះជួយកំណត់ចំនួន កត្តាចង្អុលបង្ហាញ ដែលយើងត្រូវសរសេរ ព្រោះយើងគ្រាន់តែសរសេរ កត្តាចង្អុលបង្ហាញទៅតាម កម្រិតលទ្ធផល។ ផ្តល់ឱកាស ដល់សិក្ខាកាមដើម្បីសួរសំណួរ ។ | o សិក្ខាកាមស្តាប់ការពន្យល់របស់អ្នកសម្របសម្រួល ហើយ សួរសំណួរ ។ |

# វគ្គទី ៦: ការកំណត់កត្តាខាងក្រៅ

| | |
|---|---|
| ប្រធានបទ និង ការសង្ខេប | **កត្តាខាងក្រៅ:** វគ្គនេះពន្យល់ថាតើអ្វីទៅជាកត្តាខាងក្រៅ ។វគ្គទាក់ទងនឹងការពិនិត្យថាតើបញ្ហាទាំងអស់ដែលបានកំណត់នៅក្នុងការវិភាគបញ្ហាមុនស្ថិតក្រោមការត្រួតពិនិត្យរបស់កម្រងហើយថាតើអាចសម្រេចគោលដៅបានដែររឺទេ។ ចំពោះបញ្ហាមួយចំនួនដែលមិនអាចដោះស្រាយបាន ឬគោលដៅដែលមិនអាចសម្រេចបាន អ្នកសម្របសម្រួលត្រូវជួយសិក្ខាកាមឱ្យកំណត់នូវកត្តាទាំងនេះ ហើយលុបវាចេញពីដើមឈើបញ្ហា/គោលដៅ ។នោះហើយគេហៅថា**កត្តាខាងក្រៅ** ហើយកត្តាទាំងនោះត្រូវទុកសម្រាប់ពេលក្រោយ ។ |
| ពេលវេលា: | *30 នាទី* |
| សម្ភារត្រូវការ | o គ្មាន |

| គោលដៅ | ការបង្ហាញ | សកម្មភាពរបស់សិក្ខាកាម |
|---|---|---|
| o សិក្ខាកាមអាចកំណត់កត្តាខាងក្រៅបាន ។<br>• សិក្ខាកាមអាច កំណត់បញ្ហា និងគោលដៅនៅក្នុងផែនការរបស់គាត់ ដែលឆ្ពោះទៅរកកត្តាខាងក្រៅ ។ | <u>តើអ្វីទៅជាកត្តាកំណត់ខាងក្រៅ?</u><br>o អ្នកសម្របសម្រួលឱ្យសិក្ខាកាមពិនិត្យដើមឈើបញ្ហា និងគោលដៅរបស់គាត់ ។ បន្ទាប់មកគាត់សួរថាតើមានបញ្ហាដែលមិនស្ថិតក្រោមការត្រួតពិនិត្យរបស់កម្រង និងថាតើមានគោលដៅដែលមិនអាចសម្រេចបានខ្លះរឺទេ។ ប្រសិនបើមានអ្នកសម្របសម្រួលសួរថា តើមានអ្វីខ្លះ ។ កត្តាទាំងនោះហើយ ហៅថា **កត្តាខាងក្រៅ** ។ កត្តាទាំងនោះអាចប៉ះពាល់ដល់លទ្ធផលនៃគោលដៅរយៈពេលវែងនិងខ្លី ប៉ុន្តែយើងសន្និដ្ឋានថាកត្តាទាំងនេះមិនជ្រៀតជ្រែកដល់ផែនការរបស់យើងខ្លាំងទេ ។ ដោយហេតុនេះហើយ ជួនកាលយើងហៅវាថាការសន្និដ្ឋាន កត្តាខាងក្រៅ។ ប្រសិនបើកត្តាខាងក្រៅមានសារៈសំខាន់ខ្លាំង ហើយយើងមិនអាច សម្រេចគោលដៅដោយគ្មាន ការត្រួត-ពិនិត្យ ជួនកាលគេហៅវាថា **កត្តារាំងស្ទះ** ។ ប្រសិនបើ មានកត្តាខាងក្រៅមួយចំនួនដែលជាកត្តារាំងស្ទះដែរនោះមានន័យថាផែនការរបស់យើងគឺមិនអាចសម្រេចទៅបានឡើយ ។ យើងសង្ឃឹមថាគ្មានកត្តាខាងក្រៅណាជាកត្តារាំងស្ទះទេនៅក្នុងផែនការរបស់យើង ។<br><u>រំលឹកពីដើមឈើបញ្ហា/គោលដៅ</u><br>o ផ្អែកតាមការពិនិត្យខាងលើក យើងលុបកត្តា | o សិក្ខាកាមស្តាប់ការពន្យល់អំពីកត្តាខាងក្រៅ ។<br>o សិក្ខាកាមពិនិត្យដើមឈើបញ្ហា/ គោលដៅដែលបានបង្កើតឡើងសម្រាប់កត្តាខាងក្រៅ ។<br>o សិក្ខាកាមលុបបញ្ហា/គោលដៅដែលមានទំនោរទៅរកកត្តាខាងក្រៅ ហើយរក្សាទុកចំណុចនេះ សម្រាប់ពេលលើកក្រោយ។ |

| | | |
|---|---|---|
| | ខាងក្រៅមួយចំនួនពីដើមឈើបញ្ហា/គោលដៅ ហើយរក្សាទុកប័ណ្ណដែលបានសរសេរនៅពេលក្រោយមកទៀត ។ | |

| វគ្គទី ៧: ផែនការ Matrix | |
|---|---|
| ប្រធានបទ និង ការសង្ខេប | **ការបង្កើតផែនការ Matrix:** អ្នកសម្របសម្រួលប្រើវគ្គនេះដើម្បីបង្ហាញសិក្ខាកាមនូវអ្វីដែល គេហៅថា **ការធ្វើផែនការMatrix** ។ វាគឺជាតារាងធំមួយដែលមានសមាសធាតុនៃការធ្វើផែនការដែលបានសរសេរតាំងពីមុនមក និងក្នុងពេលអនាគត ដែលយើងត្រូវមាន ។ សិក្ខាកាមបំពេញក្នុងតារាង matrix ជាមួយនឹងសមាសធាតុសំខាន់ៗដែលត្រូវសរសេរ ។ |
| ពេលវេលា: | *60 Minutes* |
| សម្ភារត្រូវការ | o គំរូ Matrix ដែលគូនៅលើក្រដាសផ្ទាំងធំ<br>o ប័ណ្ណគោលដៅ លទ្ធផល សកម្មភាព កត្តាចង្អុលបង្ហាញ ធនធានដែលបានសរសេរកាលពីមុន ។<br>o <u>ឯកសារចែកទី ៥:</u> តារាងផែនការសមហេតុផល (LFA Matrix ) |

| គោលដៅ | ការបង្ហាញ | សកម្មភាពរបស់សិក្ខាកាម |
|---|---|---|
| o សិក្ខាកាមអាចស្រង់ឈ្មោះផ្នែកទាំងអស់នៃផែនការ Matrix ។<br>• សិក្ខាកាមអាច បំពេញធាតុនៃការ ធ្វើផែនការMatrix ជាមួយខ្លឹមសារដែលបានរៀបចំកាលពីមេរៀនមុន ។ | <u>ទម្រង់ផែនការ Matrix</u><br>o ដោយសិក្ខាកាមមានបទពិសោធមួយចំនួនក្នុងការបង្កើតគោលដៅសកម្មភាព កត្តាចង្អុលបង្ហាញ ពួក-គាត់អាចចាប់ផ្តើមរៀបចំគោលដៅដាក់ចូលក្នុងទម្រង់ Matrix ។បង្ហាញឧទាហរណ៍នៃ Matrix-ទទេរមួយ ដែលបានគូរកាលពីមុននៅ លើក្រដាសធំមួយចំនួន បិតរួមគ្នា ។ បិត Matrix ដាក់លើជញ្ជាំងហើយចាប់ផ្តើមបំពេញឈ្មោះផ្នែកខុសៗគ្នាដូចខាងក្រោម:<br>1. គោលដៅរយ:ពេលវែង<br>2. គោលដៅរយ:ពេលខ្លី<br>3. លទ្ធផល<br>4. សកម្មភាព<br>5. ធនធាន<br>6. គត្តាចង្អុលបង្ហាញ<br>7. កត្តាកំណត់ខាងក្រៅ<br>o ពន្យល់ពីការកំណត់ធាតុជាគូរួមគ្នា (ឧ. អាំងឌីកាទ័រជាមួយគោលដៅ/លទ្ធផល សកម្មភាព ជាមួយធនធាន ។ល ។) ។ ផ្តល់ឱកាសឱ្យសិក្ខាកាមសួរ ។<br><u>ការបំពេញតារាងផែនការ Matrix</u> | o សិក្ខាកាមស្តាប់ការពន្យល់អំពីការធ្វើផែនការតាមតារាង Matrix ។<br>o សិក្ខាកាមសួរអំពី Matrix ។<br>o សិក្ខាកាមទុកឯកសារចែកជូននេះនៅក្នុងសៀវភៅសម្ភារវគ្គសិក្សារបស់ពួកគេ ។<br>o សិក្ខាកាមយកប័ណ្ណទាំងអស់ពីលំហាត់ធ្វើផែនការមុន មកដាក់ក្នុងតារាង Matrix ។ |

| | | |
|---|---|---|
| | o បន្ទាប់មកចែកឯកសារទី ៤ ដែលជាឯកសារយោងសម្រាប់សិក្ខាកាមទាំងអស់ដើម្បីបន្ថែមលើសម្ភារវគ្គសិក្សា ។<br>o យោងតាមការពន្យល់នេះ សុំឱ្យសិក្ខាកាមដាក់ប័ណ្ណនៃគោលដៅ លទ្ធផល សកម្មភាព ។ល។ បញ្ចូលក្នុងតារាង Matrix ។<br>o សំណូមពរដល់សិក្ខាកាមថា វាមានប្រយោជន៍ក្នុងការដែលយើងរក្សាទុកតារាង Matrix នេះ ដាក់ក្នុងទីចាត់ការសាលាបង្គោលដែលគេអាច មើលឃើញបាន ។ តារាងនោះនឹងក្លាយជាគ្រឿងរំលឹកដល់មនុស្សគ្រប់គ្នាថានេះជាផែនការប្រចាំកម្រង ។ គ្រប់គ្នានៅក្នុងកម្រងមិនត្រូវយក ផែនការនេះដាក់នៅលើតុនរណាម្នាក់បានទេ ព្រោះវាធ្វើឱ្យយើងភ្លេច ។ | |

| **វគ្គទី ៨: ការសរសេរសកម្មភាព និងការប្រើប្រាស់បញ្ជី** | | |
|---|---|---|
| **ប្រធានបទ និង ការសង្ខេប**<br><br>**ពេលវេលា:** | **៨.១. ការជ្រើសរើសសកម្មភាពដើម្បីសម្រេចគោលដៅ:** អ្នកសម្របសម្រួលពន្យល់ថានៅពេលគេបានព្រមព្រៀងលើគោលដៅសម្រាប់ផែនការ ជំហានក្រោយទៀតគឺត្រូវជ្រើសរើសសកម្មភាពណា ដែលត្រូវការដើម្បីសម្រេចនូវគោលដៅ ។ សកម្មភាពទាំងនេះត្រូវបានគេហៅថា “សកម្មភាព ” ។ អ្នកសម្របសម្រួលពន្យល់ថាសកម្មភាពត្រូវជ្រើសរើស ហើយត្រូវគ្នាជាមួយនឹងគោលដៅ បើមិនដូច្នោះទេគោលដៅនឹងមិនទទួលបានផលឡើយ ។ នៅក្នុងវគ្គនេះ អ្នកសម្របសម្រួលផ្តល់ឧទាហរណ៍មួយចំនួនដើម្បីបង្ហាញពីលក្ខណៈនៃសកម្មភាព និងគោលដៅត្រូវគ្នា ។ អ្នកសម្របសម្រួលផ្តល់ការណែនាំខ្លះៗដល់សិក្ខាកាមដើម្បីជួយពួកគាត់ឱ្យសរសេរសកម្មភាពរបស់ពួកគាត់ផ្ទាល់ ។<br><br>*60 នាទី* | |
| **សម្ភារត្រូវការ** | o <u>ឯកសារទី ៦:</u> គោលការណ៍ណែនាំសម្រាប់ការសរសេរសកម្មភាព | |
| **គោលដៅ** | **ការបង្ហាញ** | **សកម្មភាពរបស់សិក្ខាកាម** |
| o សិក្ខាកាមបង្ហាញពីការយល់ពីទំនាក់ ទំនងរវាងគោលដៅ និងសកម្មភាព តាមរយៈចំលើយរបស់ពួកគាត់ និងឧទាហរណ៍ ។<br>o សិក្ខាកាមអាចប្រើគោល- | <u>ទំនាក់ទំនងរវាងគោលដៅ និងសកម្មភាព</u><br>o អ្នកសម្របសម្រួលពន្យល់ថា សកម្មភាព (ACTION) ជាតម្រូវការចាំបាច់ដើម្បីសម្រេចបាននូវគោលដៅនៅក្នុងផែនការកម្រង ។ សកម្មភាពទាំងនេះជាធម្មតាគេហៅ ថា **សកម្មភាព** (ACTIVITIES) ។ ចូរចាំ-ចាត្រូវរំលឹកសិក្ខាកាមថា*យើងគ្រាន់តែសរសេរសកម្មភាព* | o សិក្ខាកាមស្តាប់ការណែនាំ ។ |

| | | |
|---|---|---|
| ការណែណែនាំ ដើម្បីសរសេរ សកម្មភាព ។ | *នៅក្នុងផែនការរបស់យើងសម្រាប់គោលដៅដែល យើងហៅថា **លទ្ធផល** (outputs)* តែប៉ុណ្ណោះ ។<br>o អ្នកសម្របសម្រួលបន្តថា មានប្រភេទសកម្មភាពច្រើនដែលយើងអាចធ្វើជាផែនការដើម្បីផ្គូរផ្គងជាមួយគោលដៅ ។បន្ទាប់មក អ្នកសម្របសម្រួលផ្តល់ឧទាហរណ៍មួយចំនួន ។<br>o ឧទាហរណ៍ ១: ប្រសិនបើសម្រេចគោលដៅ ត្រូវការការប្រមូលថវិកា *តើយើងអាចធ្វើផែនការលើសកម្មភាពអ្វីខ្លះ? ចំលើយ: សកម្មភាពប្រមូលថវិកា*<br>o ឧទាហរណ៍ ២: ប្រសិនបើគោលដៅគឺបង្កើនអត្រាចុះឈ្មោះរបស់សិស្សស្រីនៅក្នុងថ្នាក់ទី ៤ ៥ ៦ ។ *តើយើងអាចធ្វើផែនការលើសកម្មភាព អ្វីខ្លះ? ចំលើយ: ការប្រជុំ មាតាបិតាសិស្សស្រីថ្នាក់ទី ៣និងទី ៤ ដើម្បីសង្កត់ធ្ងន់លើសារសំខាន់នៃការឱ្យពួកគេរៀននៅសាលាបន្តទៀត ហើយរកឱ្យឃើញថាតើសាលាអាចជួយអ្វីដល់ឪពុកម្តាយសិស្ស និងក្រុមគ្រួសារ ។*<br>o ឧទាហរណ៍ ៣: ប្រសិនបើមានបញ្ហាលើការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅក្នុងកម្រង ហើយគោលដៅគឺដើម្បីកែលំអការបង្រៀននោះ *តើយើង អាចធ្វើផែនការលើសកម្មភាព អ្វីខ្លះ? ចំលើយ: អញ្ជើញគ្រូពីសាលាជិត១ហើយពូកែបង្រៀនមុខវិជ្ជានេះឱ្យធ្វើថ្នាក់ និទ្សន៍ ។*<br>ការសរសេរសកម្មភាព: គោលការណ៍ណែនាំ<br>o យោងតាមការពិភាក្សាខាងលើអ្នកសម្របសម្រួលត្រូវចែកឯកសារទី៥ដល់សិក្ខាកាមហើយរំលឹក គោលការណ៍ណែនាំខ្លះ១ក្នុងការសរសេរសកម្មភាព ។ ជាពិសេសអ្នកសម្របសម្រួលត្រូវសង្កត់ធ្ងន់លើពាក្យ ដែលមិនគួរប្រើក្នុងការសរសេរសកម្មភាព និងពាក្យដែលមិនសមរម្យ ។ សូមប្រើតារាងដែលមានចំនងជើងថា "ពាក្យ សកម្មភាពដែលមានប្រយោជន៏" ដើម្បី សម្រួលដល់ការពន្យល់ ។<br><br>ការសរសេរសកម្មភាពជាក់ស្តែង: លំហាត់<br>o នៅពេលអ្នកសម្របសម្រួលបញ្ចប់ការរំលឹកឯកសារនោះហើយ សុំឱ្យសិក្ខាកាមបំពេញលំហាត់នៅផ្នែកខាងក្រោមនៃឯកសារនោះជាក្រុមតូច ។<br>o នៅពេលសិក្ខាកាមបានបំពេញលំហាត់ចប់ គ្រូពិនិត្យ | o សិក្ខាកាមឆ្លើយតបនឹង ឧទាហរណ៍ និងសំណួររបស់ អ្នកសម្របសម្រួលតាមគំនិត និងសំណូមពររបស់ពួកគេ ។<br>o សិក្ខាកាមឆ្លើយតបនឹង ឧទាហរណ៍ និងសំណួររបស់ អ្នកសម្របសម្រួលតាម គំនិត និងសំណូមពររបស់ពួកគេ ។<br><br>o សិក្ខាកាមឆ្លើយតបនឹង ឧទាហរណ៍ និងសំណួររបស់ អ្នកសម្របសម្រួលតាមគំនិត និងសំណូមពររបស់ពួកគេ ។<br><br>o សិក្ខាកាមស្តាប់ការពន្យល់ បន្ទាប់មកអានឯកសារ ។<br><br>o សិក្ខាកាមបំពេញលំហាត់ នៅក្នុងឯកសារជាក្រុមតូច ។ នៅពេលចប់ ពួកគេត្រូវ បង្ហាញសកម្មភាពដែលបាន សរសេរ ដល់ក្រុមធំ ។ |

| | | |
|---|---|---|
| | សកម្មភាពរបស់ក្រុមនីមួយដើម្បីមើលថាតើវាសមនឹង គោលការណ៍ណែនា ំនិងប្រសិនបើវាសមនឹងដំណោះស្រាយឬទេ ។ | |

| | | |
|---|---|---|
| **ប្រធានបទ និង ការសង្ខេប**<br><br>**ពេលវេលា:** | **៨.២ ការសរសេរសកម្មភាពសម្រាប់ផែនការដោយប្រើបញ្ជី:** ក្នុងវគ្គនេះ អ្នកសម្របសម្រួលផ្តល់ពេលដល់ សិក្ខាកាមដើម្បីចាប់ផ្តើមសរសេរសកម្មភាពជាក់ស្តែងសម្រាប់ផែនការរបស់ពួកគេដោយប្រើគោលការណ៍ណែនាំ ដែលបានពិភាក្សាកាលពីមុន ។ សកម្មភាពនោះអាចជួយសិក្ខាកាមនៅក្នុងកិច្ចការនេះដោយការឡើងបង្ហាញបញ្ជីសកម្មភាពដែលអាចជួយពួកគាត់នូវ គំនិតខ្លះៗនៃសកម្មភាពដែលមាន ប្រយោជន៍ដើម្បីដោះស្រាយបញ្ហាដែល បានកំណត់ ។<br><br>*120 នាទី* | |
| **សម្ភារត្រូវការ** | o <u>ឯកសារទី ៧:</u> ការប្រើបញ្ជីដើម្បីបង្កើតសកម្មភាព<br>o <u>ឯកសារ:</u> បញ្ជីសកម្មភាព<br>o ប័ណ្ណពណ៌សម្រាប់សរសេរសកម្មភាពផ្អែកលើលទ្ធផលដែលចង់បាន | |
| **គោលដៅ** | **ការបង្ហាញ** | **សកម្មភាពរបស់សិក្ខាកាម** |
| o សិក្ខាកាមអាចសរសេរសកម្មភាពសម្រាប់ ផែនការរបស់ពួកគាត់ ដោយប្រើគោលការណ៍ ណែនាំបង្ហាញកាលពីមុន។<br>o សិក្ខាកាមអាចប្រើបញ្ជីសេវាកម្មដើម្បជួយពួកគាត់ប្រមូលសកម្មភាពដែលសមរម្យនឹងសម្រេចបានលទ្ធផលដែល បានកំណត់ និង បញ្ហាដែលត្រូវការដោះស្រាយ ។ | <u>សារសំខាន់នៃភាពខុសគ្នាក្នុងការធ្វើផែនការ</u><br>o អ្នកសម្របសម្រួលពន្យល់ថាកម្រងដែលមានបទពិសោធតិចក្នុងការធ្វើផែនការយល់ថាវាមានការលំបាកក្នុងការជ្រើសរើសសកម្មភាពដែលសមរម្យដើម្បីសម្រេចបាននូវគោលដៅ ។<br>o អ្នកសម្របសម្រួលបន្តៈដោយសារខ្វះខាតបទពិសោធកម្រងពុំសូវទុកចិត្តលើការច្នៃអ្វីដែលថ្មីឬអ្វីដែលប្លែកទេ<br>o ពេលខ្លះ ប្រសិនបើសាលាក្នុងកម្រងប្រឈមមុខលើបញ្ហាដូចគ្នា វាជាការល្អប្រសើរ ។ ប៉ុន្តែពេលខ្លះមានន័យថាកម្រងមិនបានអំពីតម្រូវការ និងបញ្ហាផ្ទាល់របស់ខ្លួនទេគឺពួកគាត់គ្រាន់តែធ្វើតាមគំនិតរបស់គេតែប៉ុណ្ណោះ។ ហេតុនេះហើយ យើងរំពឹងថាកម្រងនឹងគ្នាព្រមទាំងសាលាទាំងអស់នៅក្នុងកម្រងតែមួយផងដែរ<br>**<u>ការប្រើប្រាស់បញ្ជីសកម្មភាព</u>**<br>o វិធីមួយដែលព្យាយាមកំណត់ឱ្យច្បាស់អំពីការច្នៃប្រឌិតក្នុងការធ្វើផែនការ និងភាពខុសគ្នាក្នុងផែនការគឺត្រូវប្រើនូវអ្វីដែលយើងហៅថា **បញ្ជីសកម្មភាព** (ACTIVITY MENU) ។ បញ្ជីគឺជាតារាងនៃលទ្ធភាពសកម្មភាពដែលយើងអាច **ជ្រើសរើសបាន** ។ បញ្ជីនេះ | o សិក្ខាកាមស្តាប់ការពន្យល់របស់អ្នកសម្របសម្រួល ។<br><br>o សិក្ខាកាមអានបញ្ជីសកម្មភាពជាមួយអ្នកសម្របសម្រួលដោយសួរតាមការចាំបាច់ ។<br><br>o សិក្ខាកាមចាប់ផ្តើមសរសេរសកម្មភាពរបស់ពួកគាត់ដោយប្រើបញ្ជីសកម្មភាពដែលបានស្នើ |

| | | |
|---|---|---|
| | ដូចគ្នានឹងបញ្ជីរាយមុខម្ហូបនៅក្នុងភោជនីយដ្ឋានសម្រាប់ឱ្យអតិថិជនជ្រើសរើស ។<br>o បន្ទាប់មក អ្នកសម្របសម្រួលចែកបញ្ជីសកម្មភាព ហើយពន្យល់ពីវិធីប្រើប្រាស់វាដោយយោងតាមសេចក្តីណែនាំនៅខាងលើនៃឯកសារ ។ផ្តល់ពេលដល់សិក្ខាកាមឱ្យអានបញ្ជីសកម្មភាពទាំងអស់( ១១សកម្មភាព) ហើយ ឆ្លើយសំណួរទាំងអស់ ។<br><u>ការសរសេរសកម្មភាពសម្រាប់ផែនការ</u><br>o ដោយប្រើបញ្ជី សូមផ្តល់ពេលដល់សិក្ខាកាមដើម្បីចាប់ ់ផ្តើមសរសេរសកម្មភាពសម្រាប់ផែនការផ្ទាល់ខ្លួន។ ត្រូវចាំថាសកម្មភាពទាំងអស់គឺត្រូវសរសេរសម្រាប់តែលទ្ធផលតែប៉ុណ្ណោះ ។ ចែកសិក្ខាកាមជា២ រឺ ៣ក្រុមធំ បន្ទាប់មក សួរក្រុមនីមួយៗថាតើលទ្ធផលណាខ្លះដែលពួកគាត់ចង់សរសេរសកម្មភាពដាក់ ។ សុំឱ្យពួកគាត់សរសេរសកម្មភាពទាំងនោះនៅលើប័ណ្ណពណ៌ ។ ពិនិត្យ និងជួយតាមការចាំបាច់ ។<br>o នៅពេលពួកគាត់ធ្វើចប់ សុំឱ្យពួកគាត់បង្ហាញសកម្មភាពរបស់ពួកគាត់ដល់ក្រុមដើម្បីពិនិត្យ ។ ផ្លាស់ប្តូរប្រសិនបើចង់ ។ | o សិក្ខាកាមក្នុងក្រុមនីមួយៗបង្ហាញសកម្មភាពរបស់គាត់ដល់ក្រុមទាំងមូល ។សិក្ខាកាមដទៃទៀត ចាំផ្តល់ព័ត៌មានត្រឡប់ហើយការផ្លាស់ប្តូរអាចធ្វើបានតាម ការចាំបាច់។ |

## ផ្នែកទី ៩: ការសរសេរគន្លាចង្គុលបង្ហាញ (Indicators)

| ប្រធានបទ និង ការសង្ខេប | គន្លាចង្អុលបង្ហាញ: ក្នុងវគ្គនេះ សិក្ខាកាមនឹងរៀនអំពីតួនាទីនៃ Indicators នៅក្នុងការធ្វើផែនការ និងមូលហេតុនៃសារៈសំខាន់ក្នុងការប្រើប្រាស់គន្លាចង្អុលបង្ហាញ ។ ពួកគាត់នឹងរៀន អំពីចំណុចមួយ ចំនួននៃ Indicators និងវិធីសរសេរវា ។ ចុងក្រោយ ពួកគាត់នឹងចាប់ផ្តើមសរសេរឧទាហរណ៍ ខ្លះនៃ Indicators សម្រាប់គោលដៅដែលដកស្រង់ពីផែនការកម្រង ។ | |
|---|---|---|
| ពេលវេលា: | *៦០នាទី (សម្រាប់ការពន្យល់) និង ៦០នាទីសម្រាប់សរសេរ Indicators* | |
| សម្ភារត្រូវការ | o ឯកសារទី ៨: គោលការណ៍ណែនាំសម្រាបការបង្កើតី Indicators | |
| គោលដៅ | ការបង្ហាញ | សកម្មភាពរបស់សិក្ខាកាម |
| o សិក្ខាកាមអាចពន្យល់ ពីមូលហេតុនៃសារៈសំខាន់ក្នុងការប្រើប្រាស់ Indicators ក្នុងការផែនការ ។<br>o សិក្ខាកាមអាចពណ៌នាពី លក្ខណៈនៃ Indicators ។<br>o សិក្ខាកាមអាចសរសេរ Indicators ផ្ទាល់ខ្លួនដោយយោងលើ គោល-ការណ៍ណែនាំ ដែលបានពិភាក្សារួច ហើយនៅក្នុងសិក្ខាសាលា ។ | <u>ហេតុអ្វីបានជាយើងប្រើ Indicators</u><br>o បន្ទាប់ពីចប់ផ្នែកសរសេរសកម្មភាព អ្នកសម្របសម្រួលសួរសិក្ខាកាមថាតើពួកគាត់នឹងដឹងថា គោលដៅរបស់ពួកគាត់បានសម្រេច ឬមានប្រសិទ្ធភាពឬទេ ។ ចំពោះចំលើយខុសៗគ្នា ដែលបានមកពីសំណួរនេះ (ឧ. សិស្សបានយល់ច្រើនជាងមុន គ្រូបង្រៀនល្អជាង មុន...) អ្នកសម្រប-សម្រួលបន្តសង្កត់ធ្ងន់លើមធ្យោបាយដែលពួកគាត់នឹងដឹងពីព័ត៌មាននេះ ។<br>o អ្នកសម្របសម្រួលនិយាយបញ្ជៀតក្នុងការពិភាក្សាអំពីតួនាទីរបស់INDICATORS ក្នុងការធ្វើផែនការ ។ Indicators គឺជាឧបករណ៍ត្រួតពិនិត្យដែលប្រាប់យើងយ៉ាងពិតប្រាកដថា ពេលណាយើងអាចសម្រេចគោលដៅ ។ អាស្រ័យហេតុនេះ Indicator គឺប្រៀបដូច ជា **បទដ្ឋាន** (STANDARDS) ដែលជួយឱ្យយើងវាយតំលៃថាតើផែនការនេះទទួលជោគជ័យ ឬបរាជ័យ ។<br><u>លក្ខណៈនៃ Indicators</u><br>o ចែកឯកសារទី៨ ដើម្បីជួយសម្រួលដល់ការពន្យល់ពី Indicators ។ ឆ្លងតាមឯកសារនេះ ត្រូវកំណត់ឱ្យច្បាស់ដោយសង្កត់ធ្ងន់ថា Indica-tors ប្រើនូវបទដ្ឋានដែលអាចជាលក្ខណៈប្រព័ណ្ឌ (RELATIVE)រឺជាលក្ខណៈដាច់ខាត (ABSLUTE)ហើយបទដ្ឋានដែលយើងកំណត់ | o សិក្ខាកាមស្តាប់ការណែនាំ ។<br>o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួលជាក្រុមធំ ។<br><br>o សិក្ខាកាមអានឯកសារជាមួយអ្នកសម្របសម្រួល ។ សិក្ខាកាមសួរសំណួរប្រសិនបើពួកគាត់មានសំណួរលើឯកសារដែល បានចែកជូន ។<br><br>o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួលជាក្រុមធំ ។ |

| | | |
|---|---|---|
| | ត្រូវមានលក្ខណៈជាក់ស្តែង (REAL- ISTIC) ។លើសពីនេះទៀតការងារមួយចំនួនមានការលំបាកក្នុងការវាស់វែង ហើយពេលខ្លះយើងត្រូវប្រើអាំងឌីកាំរេង (PROXYINDICATORS) ផ្តល់ពេលឱ្យសិក្ខាកាម សួរសំណួរ ។<br>ចំណុចមួយចំនួននៃ Indicator/ការសរសេរ Indicators<br>o លើកឧទាហរណ៍នៃគោលដៅមួយដូចជា “សិស្សយល់ច្រើនអំពីមេរៀនរបស់ពួកគេ។” ហើយសួរសិក្ខាកាមអំពីវិធីដែលធ្វើឱ្យសិស្សសម្រេចបាននូវគោលដៅនៃការរៀនរបស់សិស្សនេះ ។ សរសេរចំលើយដាក់នៅលើក្តារខៀន ។ ចំលើយទាំងនោះរួមមានការមើល ការប្រលងការសម្ភាសសិស្ស ការមើលទៅលើអត្រាត្រួត ថ្នាក់របស់សិស្ស ។ល។<br>o បន្ទាប់មកអ្នកសម្របសម្រួលនិយាយថា ព័ត៌មានដែលបានទទួលពីសកម្មភាពត្រួតពិនិត្យនេះបង្ហាញយ៉ាងច្បាស់នូវលក្ខ័ណ្ឌមួយចំនួន ។ នៅពេលលក្ខ័ណ្ឌទាំងនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ យើងត្រូវបង្កើត Indicator ។ Indicators ជាធម្មតាបញ្ជាក់យ៉ាងច្បាស់នូវលក្ខ័ណ្ឌខាងក្រោមនេះ:<br>1. *កម្រិតលទ្ធផលការងារសម្រេចបាន (ឧ.ពិន្ទុសិស្ស យ៉ាងហោចណាស់ ៥/១០)*<br>2. *ច្រើនប៉ុណ្ណា?* (ឧ, 60% នៃចំនួនសិស្ស)<br>3. *សម្រាប់នរណា* (ឧ. សិស្សគ្រប់កម្រិត)<br>4. *នៅពេលណា* (ឧ. នៅដំណាច់ឆ្នាំ)<br>o បន្ទាប់មក អ្នកសម្របសម្រួលដឹកនាំសិក្ខាកាមតាមរយៈលំហាត់បង្កើតឧទាហរណ៍នៃលក្ខ័ណ្ឌ indicator ដែលបានផ្តល់ឱ្យនៅក្នុងរង្វង់ក្រចកដាក់ចូលក្នុង Indicator រួមតែមួយ ។ សិស្ស ៦០%នៅគ្រប់កម្រិតថ្នាក់ទាំងអស់អាចមានពិន្ទុយ៉ាងហោចណាស់៥០%នៅក្នុងការប្រលងផ្តាច់ព្រ័តនៅចុងឆ្នាំសិក្សា ។<br>o បន្ទាប់មក សុំឱ្យសិក្ខាកាមបំពេញលំហាត់នៅក្នុង | o សិក្ខាកាមស្តាប់ការពន្យល់ ហើយបន្ទាប់មកអានឯកសារដែលបានចែកជូន ។<br><br>o សិក្ខាកាមបញ្ចូលផ្នែកទាំងអស់ដាក់ក្នុង Indicator ពេញលេញមួយតាមការណែនាំរបស់អ្នកសម្របសម្រួល ។<br><br>o សិក្ខាកាមបំពេញលំហាត់នៅក្នុងឯកសារជាក្រុមតូច ហើយបង្ហាញដល់ក្រុមធំសម្រាប់ត្រួតពិនិត្យ ។<br><br>o សិក្ខាកាមចាប់ផ្តើមសរសេរ Indicators ដាក់ក្នុងផែនការតាមការណែនាំដែលបានផ្តល់ជូន ។ |

| | | |
|---|---|---|
| | ឯកសារជាក្រុមតូច ។នៅពេលចប់ ត្រូវពិនិត្យមើលចំលើយជាក្រុមធំ ។<br><u>ការដាក់ Indicators ក្នុងផែនការមូលដ្ឋាន</u><br>o ជាចុងក្រោយ អ្នកសម្របសម្រួលសង្កត់ធ្ងន់ថា Indicators ត្រូវបានសរសេរឡើងសម្រាប់គោលដៅរយៈពេលវែង គោលដៅរយៈពេលខ្លី និងលទ្ធផលទាំងអស់ ។ វាមិនចាំបាច់សរសេរ indicators សម្រាប់សកម្មភាព ។ ប៉ុន្តែពេលខ្លះយើងត្រូវសរសេរIndicator ច្រើនក្នុងគោលដៅមួយ ។<br>o តាមការពន្យល់ខាងលើ ត្រូវផ្តល់ឱ្យសិក្ខាកាមប្រហែល៤៥នាទីដើម្បីចាប់ផ្តើមសរសេរIndicators ពិតសម្រាប់ផែនការរបស់ពួកគាត់ ។ ពិ-និត្យមើលការងាររបស់ពួកគាត់ ហើយជួយប្រសិនបើចាំបាច់ ។ ប្រសិនពួកគាត់មិនអាចធ្វើចប់ក្នុងពេលរៀនសិក្ខាសាលានេះបានទេ ពួកគាត់ត្រូវធ្វើបន្តនៅតាមកម្រងរៀងៗខ្លួន ។ | |

| **ផ្នែកទី ១០: ធនធានសម្រាប់ផែនការ** | | |
|---|---|---|
| **ប្រធានបទ និង ការសង្ខេប**<br><br>**ពេលវេលា:** | **ការកំណត់ធនធានសម្រាប់សកម្មភាព:** វគ្គនេះពិភាក្សាអំពីប្រភេទធនធានដែលត្រូវបំពេញលើផែនការកម្រងមូលដ្ឋាន ហើយគួរតែបញ្ជាក់នៅក្នុងតារាងផែនការMatrix ។ វគ្គនេះព្រមទាំងបានផ្តល់នូវព័ត៌មានខ្លះៗ ស្តីអំពីលទ្ធភាពធនធានដែលបានមក ពីប្រភពខុសៗគ្នារួមមានអាជ្ញាធរថ្នាក់កណ្តាល សហគមន៍ និងថវិកាអង្គការ ឬឯកជន ។<br><br>*30 នាទី(សម្រាប់ការពន្យល់) និង 60 នាទី (សម្រាប់សរសេរធនធាន)* | |
| **សម្ភារត្រូវការ** | o <u>ឯកសារទី ៩: ការរៀបចំធនធានសម្រាប់ផែនការ</u><br>o ប័ណ្ណពណ៌ | |
| **គោលដៅ** | **ការបង្ហាញ** | **សកម្មភាពរបស់សិក្ខាកាម** |
| o សិក្ខាកាមអាចដកស្រង់ឧទាហរណ៍នៃ ប្រភេទធនធានខុសៗគ្នា( ឧ. មនុស្ស សម្ភារ...)<br>• សិក្ខាកាមអាចកំណត់ធនធានដែលត្រូវការសម្រាប់ផែនការកម្រងមូលដ្ឋាន នេះបើ- | <u>ប្រភេទធនធាន</u><br>o ចាប់ផ្តើមវគ្គនេះដោយពិនិត្យលើប្រភេទធនធានដែលអាចប្រើប្រាស់បានដើម្បីអនុវត្តផែនការ ។ គូសជាតារាដាក់លើក្តារខៀន ។ សង្កត់ធ្ងន់ថាប្រភេទមួយចំនួនគឺដូចគ្នា ។<br>o បន្ទាប់មក ចែកឯកសារ ហើយប្រៀបធៀប | o សិក្ខាកាមផ្តល់ឧទាហរណ៍នៃប្រភេទធនធានដែលអាចប្រើប្រាស់បានក្នុងការអនុវត្តផែនការ ។<br><br>o សិក្ខាកាមជួយអ្នកសម្របសម្រួល |

| | | |
|---|---|---|
| តាមទម្រង់ដែលបាន ស្នើសុំ ។ | ប្រភេទ ដែលបានកំណត់នៅក្នុងតារាងដែលផ្តល់ឱ្យនិងប្រភេទផ្សេងទៀតដែលមាននៅលើក្តារខៀន ។ ផ្ទៀងផ្ទាត់បញ្ជី ។<br>o បន្ទាប់ពីបានផ្ទៀងផ្ទាត់របញ្ជីរួច គូសតារាងដោយ ដាក់ចំណងជា " ប្រភេទធនធាន " ដែលបាន បង្ហាញនៅក្នុងឯកសារចែកជូន ។ ធ្វើលំហាត់នេះ ជាក្រុមធំ ដែលសិក្ខាកាមត្រូវកំណត់ឧទាហរ៍នៃ ប្រភេទធនធាននីមួយៗដែលបានដកស្រង់ពីតា- រាង ។<br><u>ទម្រង់សម្រាប់សរសេរធនធាន</u><br>o ចំពោះគោលបំណងនៃលំហាត់ធ្វើផែនការនេះ អ្នកសម្របម្រួលត្រូវសម្គាល់ថា មានទម្រង់២ ប្រភេទសម្រាប់សរសេរធនធាននៅក្នុងផែនការរួមមាន: (i) របាយការណ៍ទូទៅនៃប្រភេទធនធាន និង (ii) របាយការណ៍តាមរូបមន្តនៃធនធានដែលនាំទៅរក របាយការណ៍ហិរញ្ញវត្ថុ នៃថវិកាដែលត្រូវការ ។<br>o ពិនិត្យមើលទម្រង់ជាមួយសិក្ខាកាមដោយផ្តល់ឧទាហរណ៍ជាក់ស្តែងចេញពីឯកសារ ។ កំណត់ឱ្យបានច្បាស់ក្នុងការធ្វើលំហាត់មួយចំនួនដោយប្រើរូបមន្តគណនាធនធាន ។<br><u>ការផ្តល់ធនធានសម្រាប់ផែនការមូលដ្ឋាន</u><br>o យោងតាមលំហាត់ខាងលើ អ្នកសម្របសម្រួលត្រូវពន្យល់ម្តងទៀតអំពីវិធីទទួលថវិកាក្នុងកម្រងរបស់ពួកគាត់ (សម្គាល់: អ្នកសម្របម្រួល ត្រូវពិនិត្យមើលចំនួននេះ ជាមួយ អ្នកគ្រប់គ្រងម្មវិធីមុនធ្វើសិក្ខាសាលា) ។ ថវិកានេះនឹងត្រូវបានផ្តល់ជូនកម្រងជាប្រាក់សុទ្ធ ។<br>o អ្នកសម្របសម្រួលត្រូវកត់សម្គាល់ថា សកម្មភាពភាគច្រើននៅក្នុងបញ្ជីនឹងត្រូវបានផ្តល់ថវិកាដោយផ្ទាល់ពីថវិកាទាំងនេះ ។ ប៉ុន្តែចំពោះសកម្មភាពផ្សេងទៀត នឹងត្រូវគេផ្តល់ថវិកាពីផ្នែកដាច់ដោយឡែកមួយ ហើយមិនត្រូវបានលើកមកចុះក្នុងផែនការតាមចំនួនថវិកាទេ។ | ផ្ទៀងផ្ទាត់តារាង២នៃប្រភេទធនធាន ។<br>o សិក្ខាកាមលើកឧទាហរណ៍ច្បាស់ៗនៃធនធានសម្រាប់ប្រភេទនីមួយៗដែលបានបង្ហាញនៅក្នុងតារាងនៃឯកសារចែកជូនទី ៩ ។ សិក្ខាកាមព្យាយាមកំណត់ឧទាហរណ៍យ៉ាងហោចណាស់ឱ្យបាន ២ សម្រាប់ប្រភេទនីមួយៗដែលបានផ្តល់ឱ្យ ។<br>o សិក្ខាកាមស្តាប់អ្នកសម្របសម្រួលពន្យល់អំពីទម្រង់ប្រើសម្រាប់សរសេរធនធាន និង សួរសំណួរ ប្រសិនបើចាំបាច់ ។<br>o សិក្ខាកាមស្តាប់អ្នកសម្របសម្រួលពន្យល់អំពីទម្រង់ប្រើសម្រាប់សរសេរធនធាន និង សួរសំណួរ ។ |

| | | |
|---|---|---|
| | ឧទាហរណ៍:<br>• គ្រូសហគមន៍<br>• ការជួយព្យាបាលសិស្សពិការ<br>• ថ្នាក់ SRP<br><br>o ចំពោះសកម្មភាព៣ដែលបានរៀបរាប់ខាងលើ សិក្ខាកាមត្រូវបង្ហាញធនធានដែលត្រូវការដោយប្រើទម្រង់សាមញ្ញដែលបានរៀបរាប់ខាងលើ (ពេលគឺ មិនមែនរូបមន្តទេ) ។<br><br><u>ការសរសេរធនធាននៅក្នុងផែនការ</u><br>o បន្ទាប់មក អ្នកសម្របសម្រួលត្រូវឱ្យសិក្ខាកាមកំណត់នូវធនធានតម្រូវការសម្រាប់សកម្មភាពមួយៗដែលពួកគាត់បានកំណត់កាលពីខាងដើម ។ សុំឱ្យសិក្ខាកាមធ្វើការជាក្រុមដើម្បីសរសេរធនធានតម្រូវការសម្រាប់សកម្មភាពនីមួយៗដែលពួកគាត់បានកំណត់រួចហើយ ។ សុំឱ្យពួកគាត់សរសេរសកម្មភាពរបស់ពួកគេពីលើក្រដាសពណ៌ ។ ពិនិត្យ និងជួយតាមប្រសិនបើចាំបាច់ ។ | o សិក្ខាកាមធ្វើការជាក្រុមដើម្បីកំណត់នូវធនធានដែលត្រូវការសម្រាប់សកម្មភាពនានាដែល ពួក-គាត់ បានកំណត់កាលពីលើក មុន ។ សិក្ខាកាមសរសេរធនធា នៅ-លើក្រដាសពណ៌ ហើយបិតវាតាម-ទីកន្លែងសមរម្យនៅក្នុង តារា-ងផែនការ Matrix ដែលបាន បង្កើតឡើងវិញនៅលើក្រដាស ផ្ទាំងធំ ។ |

| ផ្នែកទី ១១: សមាសភាពពាក់ព័ន្ធ ម្ចាស់កម្មសិទ្ធិ និងការចូលរួម | | |
|---|---|---|
| ប្រធានបទ និង ការសង្ខេប<br><br>ពេលវេលា: | **១១.១. បញ្ញត្តិគន្លឹះនៃពាក្យ សមាសភាពពាក់ព័ន្ធ ម្ចាស់កម្មសិទ្ធិ និងផែនការចូលរួម:** នេះ-ជាវគ្គខ្លីមួយសម្រាប់ណែនាំជំហ៊ានក្រោយនៃខ្លឹមសារ និងកិច្ចការ ។ អ្នកសម្របសម្រួលនិយាយថាឥលូវនេះការផ្តោតលើសកម្មភាពកំពុងតែផ្លាស់ប្តូរទៅជា **នរណា** ជាអ្នកសរសេរ ផែន ការ និង បញ្ញត្តិសំខាន់:៣ គឺ **សមាសភាពពាក់ព័ន្ធ ម្ចាស់កម្មសិទ្ធិ និងផែនការចូលរួម** (Stakeholders, ownership, and participatory planning) ។<br><br>*15 នាទី* | |
| សម្ភារត្រូវការ | o គ្មាន | |
| គោលដៅ | ការបង្ហាញ | សកម្មភាពរបស់សិក្ខាកាម |

| | | |
|---|---|---|
| o សិក្ខាកាមអាចភ្ជាប់គំនិតនៃ **នរណាជាអ្នកសរសរ ផែនការអំពី បញ្ញត្តិនៃផែនការចូលរួម** ។ | o អ្នកសម្របសម្រួលពន្យល់ថា សិក្ខាកាមបានឃើញប្រភេទផែនការ និងរចនាសម្ព័ន្ធនៃផែនការយូរមកហើយ ប៉ុន្តែឥលូវនេះពួកគេនឹងគិតអំពីថាតើ **នរណាជាអ្នកសរសេរផែនការ** ។<br>o អ្នកសម្របសម្រួលនិយាយថា នៅក្នុងសកម្មភាពក្រោយៗទៀត សិក្ខាកាមនឹងរៀនអំពីបញ្ញត្តិសំខាន់ៗ ទាំង៣: (1) សមាសភាពពាក់ព័ន្ធ (stake-holders); (2) ម្ចាស់កម្មសិទ្ធ (ownership); and (3) ផែនការចូលរួម (participatory planning) | o សិក្ខាកាមស្តាប់ការណែនាំរបស់អ្នកសម្របសម្រួល ។ |

| | |
|---|---|
| **ប្រធានបទ និង ការសង្ខេប**<br><br>**ពេលវេលា:** | **១១.២. បញ្ញត្តិនៃ “សមាសភាពពាក់ព័ន្ធ” និង សមាសភាពពាក់ព័ន្ធនៅក្នុងសាលា:** នៅក្នុងវគ្គនេះ សិក្ខាកាមបញ្ជាក់អំពីការយល់ដឹងរបស់ពួកគេលើពាក្យ“**សមាសភាពពាក់ព័ន្ធ**” ។ ជាសំខាន់ សិក្ខាកាមត្រូវដឹងថា មានសមាសភាពពាក់ព័ន្ធច្រើនណាស់នៅក្នុងវិស័យអប់រំ ពោលគឺ មិនមែនមានតែមន្ត្រីក្រសួងអប់រំប៉ុណ្ណោះទេ ។ សិក្ខាកាមបំពេញកិច្ចការដែលពួកគេនឹងពិភាក្សា រកឱ្យឃើញថាតើនរណាពាក់ព័ន្ធហើយពួកគេមានចំណាប់អារម្មណ៍ និងការចែករំលែកអ្វីខ្លះនៅក្នុងវិស័យអប់រំ ។<br><br>*45 នាទី* |
| **សម្ភារត្រូវការ** | o តារាងធំដូចតារាងមួយដែលបានបង្ហាញនៅក្នុងឯកសារចែកជូន<br>o ឯកសារទី ១០: សមាសភាពពាក់ព័ន្ធ និងចំណាប់អារម្មណ៍របស់គេទាក់ទងនឹងសាលារៀន |

| គោលដៅ | ការបង្ហាញ | សកម្មភាពរបស់សិក្ខាកាម |
|---|---|---|
| o សិក្ខាកាមបកស្រាយនូវគំនិតរបស់ពួកគាត់លើពាក្យថា **សមាសភាពពាក់ព័ន្ធ** ដោយបំពេញកិច្ចការ ។<br>. | o អ្នកសម្របសម្រួលនិយាយថា សមាសភាពពាក់ព័ន្ធជា មនុស្សផ្សេងៗគ្នាដែលមានចំណាប់អារម្មណ៍ដូចគ្នានៅក្នុងវិស័យអប់រំនិងការងារនៅក្នុងសាលារៀន ។ បញ្ញត្តិនេះ មានទំនាក់ទំនងនឹង ដំណើរការនៃការធ្វើផែនការសាលារៀន ។ សមាសភាពទាំងអស់ មានការព្រួយបារម្ភ និងមតិ ហើយអាចចែករំលែកតាមវិធីផ្សេងៗគ្នា ដើម្បីអភិវឌ្ឍសាលារៀនរបស់ពួកគេ ។<br>o អ្នកសម្របសម្រួលសុំឱ្យសិក្ខាកាមសរសេរពីសមាសភាពពាក់ព័ន្ធ ផ្សេងៗគ្នា ហើយសរសេរដាក់ ក្នុងកូឡោនទី១នៃតារាង ដែលបិត នៅលើក្តារខៀន (ដូចគ្នានឹងឯកសារចែកជូន) ។ កូឡោនទី២គឺទទេ ប៉ុន្តែមានតែចំណងជើង“សមាសភាពពាក់ព័ន្ធ” ចំណាប់អារម្មណ៍ក្នុងផែនការសាលា និងការ អភិវឌ្ឍ ។”<br>o បន្ទាប់មកអ្នកសម្របសម្រួលសុំឱ្យសិក្ខាកាមជាក្រុម រួមផ្តល់គំនិតដើម្បីបំពេញកូឡោនទី២ចំពោះសមាសភាពពាក់ព័ន្ធ នីមួយៗដែល បានសរសេរឡើង ។ ក្រោយមកអ្នកសម្រួល សរសេរគំនិតរបស់សិក្ខាកាមដាក់ក្នុងតារាងធំនៅមុខបន្ទប់ ។ | o សិក្ខាកាមស្តាប់ការបកស្រាយបង្ហាញរបស់អ្នកសម្របសម្រួល ។<br>o សិក្ខាកាមដាក់ឈ្មោះ របស់សមាសភាពពាក់ព័ន្ធផ្សេងៗគ្នា<br>o សិក្ខាកាមក្រុមរួមបំ ផុសគំនិតអំពីខ្លឹម សារ នៃកូឡោនទី២ |

| | | |
|---|---|---|
| | o អ្នកសម្របសម្រួលចែកឯកសារ ហើយឱ្យសិក្ខាកាម បំពេញក្នុងតារាងដូចគ្នាមួយ-ដើម្បីទុកប្រើជាឯកសារ យោងនៅពេលក្រោយ ។ | ដោយប្រើឯកសារចែក ជូន ។<br>o សិក្ខាកាមកត់ត្រាចំលើយដែលផ្តល់ឱ្យនៅក្នុង ឯកសាររបស់ពួកគាត់ |

**ចំលើយត្រៀមទុកជាមុនចំពោះកិច្ចការ(ការបញ្ចប់ឯកសារចែកជូន)**

| សមាសភាពពាក់ព័ន្ធ | ហេតុអ្វីបានជាសមាសភាពពាក់ព័ន្ធមានចំណាប់អារម្មណ៍ក្នុងការធ្វើផែនការសាលា និងការអភិវឌ្ឍ |
|---|---|
| ឪពុកម្តាយ | o អនាគតកូនរបស់ពួកគាត់ពឹងផ្អែកលើគុណភាពនៃការអប់រំ ។<br>o ឪពុកម្តាយផ្តល់លុយផ្ទាល់ខ្លួនដើម្បីជួយដល់សាលាតាមវិធីផ្សេងៗគ្នា ហើយចង់ដឹងថាតើសាលា មានការគ្រប់គ្រងល្អឬទេ ។ |
| គ្រូបង្រៀន | o ការបង្រៀនគឺជាមធ្យោបាយនៃការរស់នៅ ហើយពួកគេចង់ធ្វើវាឱ្យល្អ ។<br>o គ្រូបង្រៀនចង់បានការផ្គត់ផ្គង់សម្ភារល្អៗ ហើយនងធនធាផ្សេងៗទៀត ។<br>o គ្រូបង្រៀនចង់ឃើញការកែលំអលើការសិក្សា ។ |
| នាយកសាល | o វាជាមធ្យោបាយរស់នៅ ហើយពួកគាត់ចង់ធ្វើការងារនេះឱ្យបានល្អ ។<br>o មានការទទួលខុសត្រូវលើបុគ្គលិក និងសហគមនចសម្រាប់គុណភាពរបស់សាលារៀន និងជាពិសេស ការរៀបចំ និងការគ្រប់គ្រង ។ |
| សហគមន៍ | o អនាគតរបស់សហគមន៍ពឹងផ្អែកលើគុណភាពអប់រំ ពោលគឺពួកគាត់ចង់ឃើញសាលាមានការកែ លំអ និង-មានដំណើរការ និងធនធានល្អៗ ។ |
| សមាគមមាតាបិតាសិស្ស | o ពួកគាត់រៃអង្គាសលុយ ហើយធ្វើអ្វីៗដើម្បីជួយដល់សាលារៀន ពួកគេចង់ឱ្យសាលារៀនមាន ការគ្រប់គ្រងល្អ និងចេះប្រើប្រាស់សម្ភារធនធានសមស្រប ។ |
| សិស្ស | o មកសាលារៀនរៀងរាល់ថ្ងៃរយៈពេល៩ខែក្នុង១ឆ្នាំ ពួកគេចង់សប្បាយរីករាយ មានសុខភាពល្អ និងមានសុវ-ត្ថិភាព ។<br>o មានសាលារៀនសម្រាប់ពួកគេរៀននៅជំនាន់ក្រោយៗទៀត ។ ការសិក្សាត្រូវមានគុណភាពល្អ បើមិនដូច្នោ-ះទេពួកគេនឹងមានផលវិបាក ។ |
| ក្រសួង | o ផ្តល់ប្រាក់បៀវត្ស និងការចំណាយផ្សេងៗ ពួកគេចង់ឃើញលទ្ធផលល្អសម្រាប់ការចំណាយនេះ ហើយសង្ឃឹមថានឹងមានការគ្រប់គ្រង និងការរៀបចំល្អ ។ |
| អាជ្ញាធរមូលដ្ឋាន | o ពួកគេចង់ឃើញការគ្រប់គ្រង និងលទ្ធផលល្អនៃការអប់រំសម្រាប់សិស្សនៅក្នុងស្រុករបស់ ពួកគាត់ ។ |
| វត្ត ព្រះសង្ឃ | o គណៈកម្មការវត្តចំណាយលុយសម្រាប់ថែរក្សា និងពង្រីកសាលា ហើយចង់ដឹងថាតើវាមាន ការគ្រប់គ្រង និងរៀបចំល្អឬទេ ។ |
| | o |

| ប្រធានបទ និង ការសង្ខេប<br><br><br><br><br><br>ពេលវេលា: | **១១.៣ អារម្មណ៍របស់ម្ចាស់កម្មសិទ្ធិ:** នេះជាវគ្គខ្លីដែលអ្នកសម្របសម្រួលមានតួនាទីប្រើសំណួរសួរដល់ក្រុមទាំងមូលនៃសិក្ខាកាមដើម្បីធ្វើឱ្យពួកគាត់ចងចាំអំពីសារៈសំខាន់នៃអារម្មណ៍របស់ម្ចាស់កម្មសិកទ្ធិក្នុងចំណោមសមាសភាពពាក់ព័ន្ធក្នុងជួរអប់រំ និងកម្រង ។ បន្ទាប់ពីបានព្រមព្រៀងលើអត្ថន័យនៃម្ចាស់កម្មសិទ្ធិ និងការពិភាក្សាអំពីបុគ្គលិកលក្ខណៈ មួយចំនួន សិក្ខាកាម-គិតអំពីផលប្រយោជន៍ ដល់កម្រង ប្រសិនបើអារម្មណ៍របស់ម្ចាស់កម្មសិទ្ធិមានលក្ខណៈ ទូលំទូ-លាយហើយ ។<br><br>*30 នាទី* | |
|---|---|---|
| សម្ភារត្រូវការ | o គ្មាន | |
| គោលដៅ | ការបង្ហាញ | សកម្មភាពរបស់សិក្ខាកាម |
| o សិក្ខាកាមអាចពន្យល់ ពីបញ្ញត្តិនៃពាក្យ **ម្ចាស់កម្មសិទ្ធិ** និងទំនាក់-ទំនងរបស់វា ។<br>o សិក្ខាកាមអាចដឹងពីផលប្រយោជន៍ ដែលបានមកពីមនុស្ស ផ្សេងៗគ្នា ដែលមានអារម្មណ៍ ថាខ្លួនជាម្ចាស់សាលា ។ | o អ្នកសម្របសម្រួលនិយាយអំពីអ្នកដែលមានអារម្មណ៍ថាខ្លួនជាម្ចាស់នៃផ្ទះមួយ ស្រែមួយ រឺកង់មួយ ។ អ្នកសម្របសម្រួលសួរ:<br>"ហេតុអ្វីបានជាមនុស្ស មានអារម្មណ៍ថាខ្លួនជាម្ចាស់កម្មសិទ្ធិនៃរបស់អ្វីមួយ?"<br>o <u>ចំលើយ:</u> ជាធម្មតាមនុស្សមានអារម្មណ៍ថាខ្លួនជាម្ចាស់កម្មសិទ្ធិ នៅពេលពួកគេទទួលបាននូវកេរ្តិ៍មរតកអ្វីម្យ៉ាង ឬខ្លួនឯងចំណាយលុយទិញវត្ថុអ្វីមួយ ។បន្ទាប់មកអាចសម្រេចចិត្តអំពីវត្ថុនោះ ។<br>o ក្រោយមកអ្នកសម្របសម្រួលសួរ:<br>"តើមនុស្សសំដែងអាកប្បកិរិយាចំពោះវត្ថុដែលជាកម្មសិទ្ធិរបស់គេយ៉ាងដូចម្តេច? "<br>o <u>ចំលើយ:</u> គេមើលថែរក្សាវា ជួសជុលវា ប្រសិនបើវាខូច ប្រើវាច្រើន ហើយមើលខុសត្រូវក្នុងការទុកដាក់វាឱ្យបានល្អ ។<br>o អ្នកសម្របសម្រួលសួរ:<br>"តើអ្វីទៅធ្វើឱ្យអារម្មណ៍របស់ម្ចាស់កម្មសិទ្ធិប្រែជាខ្សោយ?"<br>o <u>ចំលើយ:</u> ប្រសិនបើអ្នកចំណាយលុយទិញអ្វីមួយ ហើយបន្ទាប់មានអ្នកផ្សេងប្រើប្រាស់វាគ្រប់ពេល ហើយចេះសម្រេចលើវត្ថុនោះអារម្មណ៍របស់ជាម្ចាស់នឹងកាន់តែបាត់បង់ទៅៗរហូតអស់ ។ ម្ចាស់កម្មសិទ្ធិចង់សម្រេចចិត្ត លើវត្ថុ | o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួល អំពីអារម្មណ៍របស់ម្ចាស់កម្មសិទ្ធិ ។<br>o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួល អំពីអារម្មណ៍របស់ម្ចាស់កម្មសិទ្ធិ ។<br>o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួល<br>o សិក្ខាកាមឆ្លើយសំណួររបស់អ្នកសម្របសម្រួល |

| | | |
|---|---|---|
| | នោះគ្រប់យ៉ាងដែលនេះជាអារម្មណ៍ពិតរបស់ម្ចាស់ ។<br>o អ្នកសម្របសម្រួលសួរៈ<br><br>ប្រសិនបើយើងមានអារម្មណ៍ជាម្ចាស់ តើយើងរំពឹងថានឹងឃើញអ្វី? ”<br>o ចំលើយៈ បុគ្គលិកប្រចាំសាលាធ្វើការងារល្អ ហើយលំបាកក្នុងការបែងចែកថវិកា ពលកម្ម ផ្តល់សម្ភារសម្រាប់កែលំអបរិស្ថានសាលារៀន លើកទឹកចិត្តសិស្សឱ្យមករៀន និងរៀនបានជាប់លាប់ ជួយសិស្សឱ្យធ្វើកិច្ចការផ្ទះ ។ល។ | |

| | | |
|---|---|---|
| ប្រធានបទ និង ការសង្ខេប<br><br>ពេលវេលាៈ | **១១.៤. ប្រភេទនៃការគ្រប់គ្រងដែលមានលក្ខណៈចូលរួម និងមិនចូលរួមៈ** នេះជាវគ្គដែលមានរយៈពេលវែង ព្រោះវាមានសារៈសំខាន់ក្នុងការអភិវឌ្ឍប្រភេទថ្មីនៃការគ្រប់គ្រង និងការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន ។ អ្នកសម្របសម្រួលសុំឱ្យសិក្ខាកាមមួយចំនួនសំដែងតួជានាយកសាលា គ្រូបង្រៀន និងសមាជិកសហគមន៍ ។ ការសំដែងតួលើកដំបូង គឺត្រូវទទួលការគ្រប់គ្រងដោយនាយកសាលាដែលបានជជែកគ្នានៅគ្រប់ពេលវេលា រំខានគេឯង មិនឆ្លើយសំនួរ និងសម្រេចចិត្តលើគ្រប់អ្វីៗទាំងអស់ ។ ក្នុងការសំដែងតួលើកទី២ គ្រប់គ្នាត្រូវជជែកគ្នា នាយកសាលាស្តាប់ និងសួរ ពួកគេទាំងអស់គ្នាយល់ស្របគំនិតគ្នានូវអ្វីដែលត្រូវ ។បន្ទាប់ពីការសំដែងតួរួច អ្នកសម្របសម្រួល ជួយសិក្ខាកាឱ្យពណ៌នាអំពីលក្ខណៈនៃប្រភេទនៃការគ្រប់គ្រងដែលមានលក្ខណៈចូលរួម និងមិនចូលរួម ហើយសង្ខេបដោយប្រើឯកសារចែកជូន ។<br><br>*60 នាទី* | |
| **សម្ភារត្រូវការ** | o ក្តារខៀនរឺ ក្រដាសផ្ទាំងធំ<br>o ឯកសារទី ១១ៈ លក្ខណៈនៃប្រភេទនៃការគ្រប់គ្រងដែល មានលក្ខណៈចូលរួម និងមិនចូ-លរួម | |
| **គោលដៅ** | **ការបង្ហាញ** | **សកម្មភាពរបស់សិក្ខាកាម** |
| o សិក្ខាកាមអាច កំណត់លក្ខណៈនៃប្រភេទនៃការគ្រប់គ្រងដែលមានលក្ខណៈ ចូលរួម និងមិនចូលរួម ។<br>o សិក្ខាកាមអាចពន្យល់ពីទំនាក់ទំនងរវាងការ សម្រេចចិត្តដែលមានលក្ខណៈចូលរួម និងអារម្មណ៍របស់ម្ចាស់កម្មសិទ្ធិ ។ | ការសំដែងតួ និងសំណួរ<br>o អ្នកសម្របសម្រួលរៀបចំការសំដែងតួខ្លីមួយដែលមានការចូលរួមពីសិក្ខាកាម( ធ្វើផែនការទុកជាមុន) ។ មុនពេលសំដែងតួ អ្នកសម្របសម្រួលនិយាយ ទៅកាន់សិក្ខាកាមដែលចាំអង្កេតមើលការសំដែងតួថាសកម្មភាពនេះនឹងបង្ហាញឱ្យឃើញនូវវិធីពីរយ៉ាងខុសៗគ្នានៃការធ្វើសេចក្តីសម្រេចចិត្ត ។ អ្នកសម្របសម្រួលសុំឱ្យសិក្ខាកាមអង្កេតៈ<br>(1) នរណានិយាយច្រើនជាងគេ<br>(2) គំនិតរបស់នរណាដែលអ្នកបានលឺនិងកំពុងពិ | o សិក្ខាកាមដែលគេបានជ្រើសរើសមួយចំនួនជួយក្នុងការសំដែងតួនេះ ។<br>o សិក្ខាកាមផ្សេងទៀតចាំ អង្កេតការសំដែងតួនោះ ។<br><br>o សិក្ខាកាមផ្តល់ព័តិមានដល់ |

| | | |
|---|---|---|
| | ភាក្សា<br>(3) ការសម្រេចចិត្តអ្វីដែលកំពុងកើតមាន *និង*<br>(4) នរណាកំពុងសម្រេចចិត្ត<br>o បន្ទាប់ពីធ្វើការសម្រេចចិត្ត អ្នកសម្របសម្រួលសុំឱ្យសិក្ខាកាមផ្តល់ព័ត៌មានតាមរយៈការអង្កេតរបស់ពួកគាត់នៅក្នុងចំលើយនៃសំណួរដែលបានផ្តល់ឱ្យនៅខាងលើ ។ អ្នកសម្របសម្រួលសរសេរព័ត៌មាន ត្រឡប់របស់សិក្ខាកាមដាក់ក្នុងតារាងដែលមានពីគ្រូឡោននៅលើក្ដារខៀន ។<br>o អ្នកសម្របសម្រួលពន្យល់ថា វិធីពីរយ៉ាងនៃការធ្វើសេចក្ដីសម្រេចចិត្តជាធម្មតាគេហៅថា "វិធីចូលរួម" និង "វិធីដែលគ្មានការចូលរួម" ប្រសិនបើនរណាម្នាក់ ឬក្រុមតូចណាមួយគ្រប់គ្រងលើការធ្វើសេចក្ដីសម្រេចចិត្ត ហើយអ្នកដទៃមិនបានចូលរួម ក្នុងការភិភាក្សា ឬទស្សនរបស់ពួកគាត់ត្រូវបានគេទុកចោល នោះអារម្មណ៍របស់ម្ចាស់កម្មសិទ្ធិ នឹងមានភាពខ្សោយ រីឯលទ្ធផលចុងក្រោយនឹងមានភាពផ្ទុយស្រឡះ ។ គេនឹងសម្រេចចិត្តថាមិនជួយទេ ពីព្រោះតែមានវិធីបែបនោះ ។<br>o អ្នកសម្របសម្រួលបន្តថា វិធីដែលមានការចូលរួម (PARTICIPATORY STYLE) គឺមិនខុសគ្នាទាំងស្រុងទេ ព្រោះអ្នកទាំងឡាយនៅស្ថានអាជ្ញាធររដ្ឋព្យាយាមដោះស្រាយបញ្ហាការគ្រប់គ្រងជាមួយអ្នកចូលរួមផ្សេងៗជាច្រើនទៀត ហើយស្តាប់គំនិតរបស់ពួកគេ ។ ជាដំបូងពួកគាត់មិនផ្តល់គំនិតផ្ទាល់ខ្លួនរបស់ពួកគាត់ទេ ហើយសួរថាតើ ពួកគេយល់ព្រម ឬក៏អត់ ។ ពួកគេមិនរំពឹងថាមនុស្សទាំងនោះផ្តល់គំនិតរបស់គេដោយគ្មានព័ត៌មាន និងឱកាសដើម្បីពិភាក្សាជាមួយគា ។ ការគ្រប់គ្រងដែលមានការចូលរួម (Participatory Management) រួមចំណែកក្នុងការបង្កើតព័ត៌មានដែលសមស្រប និងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សា ។ ជាញឹកញាប់ វាមានន័យថា ការរៀបចំការប្រជុំជា លើដំបូងដើម្បីផ្តល់ព័ត៌មាន និងរៀបចំ | អ្នកសម្របសម្រួលនៅពេលការសំដែងតួចប់ស្តីអំពីលក្ខណៈនៃវិធីគ្រប់គ្រងពីរយ៉ាងដែលបានបង្ហាញ ។<br>o សិក្ខាកាមក្រុមធំធ្វើការបំផុសគំនិតលើខ្លឹមសារដាក់ក្នុងតារាងដែលបានគូរលើក្ដារខៀន ឬលើកក្រដាសផ្ទាំងធំ ។<br>o សិក្ខាកាមអានឯកសារ ហើយទុកឯកសារនោះធ្វើជាឯកសារយោង ។ |

| | | |
|---|---|---|
| | ការប្រជុំ ម្តងទៀតដល់ពួកគាត់សម្រាប់ពិភាក្សា និងក្រោយមក ការប្រជុំជាលើកទី៣ដើម្បីឈានសម្រេចបាននូវការព្រមព្រៀងមួយ ។ វាជាវិធីដ៏ល្អនៃការពង្រឹងនូវអារម្មណ៍របស់ម្ចាស់កម្មសិទ្ធិ (OWNERSHIP) ។<br>o អ្នកសម្របសម្រួលចែកឯកសារសង្ខេបនូវការពិភាក្សាដែលពណ៌នាអំពីវិធីផ្សេងៗគ្នានៃការគ្រប់គ្រង។ សិក្ខាកាមដាក់ឯកសារទុកក្នុងសឺមី ធ្វើ-ជាឯកសារយោង ។ | |

**ចំលើយសង្ខេបនៅក្នុងឯកសារចែកជូន**

| ការគ្រប់គ្រងដែលគ្មានការចូលរួម<br>**(on-Participatory Management)** | ការគ្រប់គ្រងដែលមានការចូលរួម<br>**(Participatory Management)** |
|---|---|
| មនុស្សគ្រប់គ្នាតែងធ្វើការសម្រេចចិត្តលើអ្វីមួយ ។ | ការសម្រេចចិត្តត្រូវបានធ្វើឡើងរហូតទាល់តែការពិភាក្សាត្រូវបានបង្កើត ហើយយោបល់ផ្សេងៗគ្នាត្រូវបានផ្តល់ឱ្យ។ |
| មានការផ្តល់ព័ត៌មានជាច្រើន ឬការពិភាក្សា ។ | ព័ត៌មានត្រូវបានផ្លាស់ប្តូរគ្នាទៅវិញទៅមក ហើយមាន ពេលវេលាគ្រប់គ្រាន់សម្រាប់ពិភាក្សា ។ |
| ប្រសិនបើគេរៀបចំការប្រជុំដែលមានការពិភាក្សាតិច ឬ មាន ឯកសារស្មុគស្មាញច្រើន ឬមានគេឱ្យយើងសម្រេចចិត្តឱ្យបាន លឿនដែលមានការពិភាក្សាតិច ។ | អ្នកទាំងនោះត្រូវបានផ្តល់ពេលវេលាសម្រាប់ជជែក ឬ អានឯកសារ ជួបពិភាក្សាជាមួយអ្នកដទៃ ហើយបន្ទាប់មកទៀតបែរមកពិភាក្សាអំពីគំនិតរបស់ពួកគេវិញ ។ |
| មន្ត្រីអាជ្ញាធរជួយផ្តល់គំនិតរបស់ពួកគេជាដំបូង ហើយសួរថាតើគ្រប់គ្នាយល់ព្រមឬទេ ។ | អ្នកគ្រប់គ្រងល្អត្រូវស្តាប់ការពិភាក្សា ហើយព្យាយាមផ្តល់យោបល់ល្អៗឱ្យបានច្រើនក្នុងក្រុមតាមដែលអាចធ្វើ បាន ។ |
| គេរំពឹងថាគ្រប់គ្នាធ្វើតាមការសម្រេចចិត្តដូចដើមយ៉ាងពិតប្រាកដលើគ្រប់ចំណុចទាំងអស់ ។ | ការសម្រេចចិត្តត្រូវបានត្រួតពិនិត្យ ឬចំណុចទាំងឡាយអាចបត់បែនតាមពេលវេលាសមស្រប ដរាបណាគោលបំណងចម្បងត្រូវបានទទួលស្គាល់ ។ |
| មានការត្រួតពិនិត្យ និងតាមដានលើការសម្រេចចិត្តតិចណាស់ដែលបានធ្វើឡើង ។ | មានការពិភាក្សាជាលក្ខណៈបើកចំហ ហើយការត្រួតពិនិត្យ ដើម្បីតាមដានការពិភាក្សាត្រូវបាបធ្វើឡើង ។ |
| | |

| **វគ្គទី ១២: តារាងGANT Charts** | |
|---|---|
| **ប្រធានបទ និង ការសង្ខេប** | **ពេលកំណត់ និងតារាង/និងមនុស្សGANT ដែលទទួលខុសត្រូវ:** នៅក្នុងវគ្គនេះ សិក្ខាកាមបំពេញការធ្វើផែនការដំណាក់កាលចុងក្រោយរបស់ពួកគេ ។ សិក្ខាកាមរៀបចំគម្រោង ពេ-លវេលារយ:ពេលមួយឆ្នាំសម្រាប់ការអនុវត្តនៃផែនការរយ:ពេល១២ខែ ។ ក្នុងការងារ នេះពួកគាត់ត្រូវសរសេរនូវសកម្មភាពនីមួយៗដាក់ចូលទៅក្នុងតារាង GANT Chart នៅពេល- |

<table>
<tr><td>ពេលវេលា:</td><td colspan="2">ការងារនេះត្រូវបានធ្វើរួច ហើយចាត់ចែងថាតើនរណាជាអ្នកទទួលខុសត្រូវ ។<br><br>*90 នាទី*</td></tr>
<tr><td>សម្ភារត្រូវការ</td><td colspan="2">o ក្រដាសផ្ទាំងធំ ហ្វឺត និងស្កុត<br>o ឯកសារ: ក្រដាសGANT Chart<br>o ការបង្កើតឡើងវិញនៃក្រដាសGANT Chart នៅលើក្រដាសផ្ទាំងធំ</td></tr>
<tr><td>គោលដៅ</td><td>ការបង្ហាញ</td><td>សកម្មភាពរបស់សិក្ខាកាម</td></tr>
<tr><td>o សិក្ខាកាមអាច អភិវឌ្ឍផែនការអនុវត្តការងារ ដោយប្រើ GANT chart ។<br>o សិក្ខាកាមអាច កំណត់ថាតើនរណាទទួល ខុសត្រូវលើការអនុវត្តសកម្មភាពនីមួយៗដែលបានស្នើឡើង ។</td><td>អំពី GANT Charts<br>o ជំហ៊ានចុងក្រោយនៃការបង្កើតផែនការ ប្រចាំឆ្នាំ អ្នកសម្របសម្រួលចែកសិក្ខាកាមឱ្យធ្វើ ផែន-ការអនុវត្តការងារ ។.<br>o ផែនការអនុវត្តការងារអាចជួយឱ្យអ្នកធ្វើផែនការដឹងអំពីពេលវេលា ដែលត្រូវធ្វើសកម្មភាព និងអ្នក ទទួលខុសត្រូវ ។ នៅពេលផែនការនោះត្រូវបានគេដាក់ក្នុងកន្លែងសាធារណៈ ពួកគេជួយធានាថាគ្រប់គ្នាដឹងថាតើអ្វីមួយនឹងកើតឡើងនៅពេលណាហើយនរណាធ្វើវា ។ មានន័យថាវាបង្កើតឱ្យមានអ្នកទទួលខុសត្រូវពិសេសសម្រាប់ការអនុវត្តសកម្មភាពទាំងនោះ ។<br>o ចែកឯកសារដល់សិក្ខាកាម ហើយប្រាប់ថាផែនការតាមទម្រង់នេះ គេហៅថា GANT chart ។ ពិ-និត្យថាតើមានសិក្ខាកាមប៉ុន្មាននាក់ ដែលធ្លាប់ ប្រ-បីប្រាស់ GANT Chart មុនពេល ជួយសម្រប-សម្រួលដល់ការពន្យល់អំពីរបៀបបំពេញ ។<br>o ដាក់ GANT chart ដែលបង្ហាញនៅក្នុងឯកសារនៅលើក្តារខៀនសម្រាប់សិក្ខាកាមមើល ។ ពន្យល់ដោយសង្ខេបអំពីការសរសេរឈ្មោះសកម្មភាព អ្នកទទួលខុសត្រូវ និងវិធីបង្ហាញ ពេលវេលា ។<br>ការបង្កើតផែនការអនុវត្តជាក់ស្តែង<br>o យោងតាមការពន្យល់ខាងលើ ត្រូវឱ្យសិក្ខាកាមអភិវឌ្ឍផែនការអនុវត្តសកម្មភាពជាក់ស្តែង ដោយប្រើទម្រង់ GANT chart នៅលើ poster ។ ប្រើតារាងដែលអ្នកសម្របសម្រួល បានគូរឡើង ។</td><td>o ពិនិត្យលើឯកសារ<br>o លំហាត់ក្រុមធំ: ជាក្រុមធំ សូមសរសេរសកម្មភាពនីមួយៗចេញពីផែនការមូលដ្ឋានដាក់ក្នុង GANT chart ដែលបានគូរដាក់លើ poster ។ សុំឱ្យសិក្ខាកាម (ប្រហែល ប្រធានក្រុម)ដឹកនាំបង្កើតផែនការ ។<br>o នៅពេលសិក្ខាកាមបានបំពេញផែនការចប់ ចូរកំណត់ថាតើ</td></tr>
</table>

| | | |
|---|---|---|
| | ធ្វើសកម្មភាពនេះជាក្រុមធំ ។<br>o នៅពេលសរសេរសកម្មភាពទាំងនេះវាមាន សារៈសំខាន់ក្នុងការបង់លេខយោងនៃ សកម្មភាព (1.1, 1.2, ...) ដើម្បីសម្គាល់នូវសកម្មភាពនីមួយៗ ទៅនឹងលទ្ធផលដែលបានចុះ ក្នុងផែនការ Matrix ។ | នរណានឹងទទួលខុសត្រូវលើការអនុវត្តសកម្មភាពនីមួយៗ ។ |

| **វគ្គទី ១៣: ជំហ៊ានបន្ទាប់** | | |
|---|---|---|
| **ប្រធានបទ និង ការសង្ខេប**<br><br>**ពេលវេលា:** | **ជំហ៊ានបន្ទាប់:** នេះជាវគ្គខ្លីមួយសម្រាប់កំណត់ឱ្យច្បាស់ថា ដំណើរការធ្វើផែនការមិនទាន់ចប់នៅឡើយទេនៅក្នុងសិក្ខាសាលានេះ ។ វគ្គនេះមានតួនាទីពិនិត្យមើលការសង្ឃឹមទុកនៃអ្នកសម្របសម្រួល និងជំហ៊ានក្រោយៗទៀតដែលអ្នកពាក់ព័ន្ធទាំងឡាយត្រូវរៀបចំ នៅពេលពួកគាត់ត្រឡប់ទៅសាលារៀន និងសហគមន៍របស់ខ្លួនវិញ ។<br><br>*30 នាទី* | |
| **សម្ភារត្រូវការ** | o <u>ក្រដាសផ្ទាំងធំ:</u> បញ្ជីនៃជំហ៊ានបន្ទាប់ | |
| **គោលដៅ** | **ការបង្ហាញ** | **សកម្មភាពរបស់សិក្ខាកាម** |
| o សិក្ខាកាមអាច លើកឡើងពីអ្វីដែល ពួកគាត់ ត្រូវធ្វើនៅពេលពួកគាត់ ត្រឡប់មកសាលា និងសហគមន៍ របស់ខ្លួនវិញ ។ | o ចាប់ផ្តើមវគ្គនេះដោយរំលឹកសិក្ខាកាមថាដំណើរការនៃការធ្វើផែនការនេះគួរត្រូវបានបញ្ចប់ដោយ សិក្ខាសា-លានេះ ។<br>o បង្ហាញ Poster ដែលសង្ខេបពីជំហ៊ានបន្ទាប់ដែល ត្រូវ-ធ្វើដើម្បីបំពេញនូវដំណើរការនៃការធ្វើ ផែនការ ។<br><br>**<u>ជំហ៊ានបន្ទាប់:</u>**<br>• បំពេញ **តារាងផែនការលំអិត** ប្រសិនបើកិច្ចការ នេះមិនទាន់ត្រូវបានបំពេញរួចរាល់ក្នុង ពេលសិក្ខាសា-លា ។<br>• ដាក់ខ្លឹមសារផែនការ Matrix នៅក្រដាសA4 ។<br>• ថតចម្លងផែនការ ហើយចែកទៅសាលានីមួយៗ មួយច្បាប់ក្នុងមួយសាលា ។<br>• ចែកឯកសារថតចម្លងដល់ក្រុមការងារថ្នាក់ខេត្ត (PWG) ដើម្បីពិនិត្យ ។<br>• ធ្វើការផ្លាស់ប្តូរ (ប្រសិនបើត្រូវការ) លើផែន ការ-តាមដែល PWG បានណែនាំ ។<br>• បញ្ជូនផែនការដែលបានរំលឹកនោះម្តងទៀត (ប្រសិ- | o សិក្ខាកាមស្តាប់ការណែនាំរបស់អ្នកសម្របសម្រួល ។<br>o សិក្ខាកាមសួរប្រសិនបើឆ្ងល់ |

| | | |
|---|---|---|
| | នបើចាំបាច់) ។<br>• ចូលរួមក្នុងសិក្ខាសាលាអំពីទម្រង់ចំណាយថវិកា (ចុងខែកញ្ញា) (តំណាងតែ៣នាក់)<br>• រៀបចំការប្រជុំនៅដើមឆ្នាំសិក្សាសម្រាប់ បុគ្គលិក និងសមាជិកសហគមន៍ទាំងអស់ក្នុង កម្រង ដើម្បីផ្សព្វផ្សាយខ្លឹមសារផែនការ ។<br>o ពន្យល់ជំហ៊ាន ឬសកម្មភាពនីមួយៗដែលត្រូវធ្វើ ។<br>o ផ្ដល់ឱកាសដល់សិក្ខាកាមសម្រាប់សួរសំណួរ ។ | |